# សេចក្ដីប្រោស លោះក្នុង ព្រះគ្រីស្ទ

លោក សែនឌី វីលសុន Sandy Willson

កូនសៀវភៅដៃគូក្នុងដំណឹងល្អ
http://www.dkdl.org

**Christ's Redemption**

Copyright © 2012 by The Gospel Coalition

Published by Crossway

a publishing ministry of Good News Publishers

Wheaton, Illinois 60187, U.S.A.

This edition published by arrangement with Crossway.

All rights reserved.

This project was accomplished in partnership with The Gospel Coalition International Outreach.

# មាតិកា


ព្រះគ្រីស្ទជាព្រះរាជបុត្រាដ៏អស់កល្ប ៦

ព្រះគ្រីស្ទជាព្រះអង្គសង្គ្រោះរបស់យើងដែលបន្ទាបខ្លួន ៨

ព្រះគ្រីស្ទជាព្រះអម្ចាស់ដែលបានលើកតម្កើង ១៤

ព្រះគ្រីស្ទជាអ្នកតំណាងនិងអ្នកជំនួសរបស់យើង ២០

ព្រះគ្រីស្ទជាសេចក្តីសង្ឃឹមតែមួយគត់របស់យើង ២៧

នៅពេលកូនប្រុសម្នាក់របស់ខ្ញុំបានបញ្ចប់ការសិក្សានិងទទួលសញ្ញាប័ត្រមហាវិទ្យាល័យរបស់គាត់តែងតែប្រារព្ធធ្វើកម្មវិធីមួយដើម្បីសរសើរនិងលើកទឹកចិត្តដល់ថ្នាក់ដែលត្រូវទទួលសញ្ញាប័ត្រ។ ជាប្រវត្តិសាស្ត្រ កម្មវិធីទាំងនេះត្រូវបានបង្កើតឡើងប្រយោជន៍ដើម្បីអោយអ្នកបម្រើដំណឹងល្អមានឱកាសចែកចាយសេចក្តីអធិប្បាយ។ ប៉ុន្តែសព្វថ្ងៃនេះបើសិនស្ថាប័នសិក្សាអប់រំមិនជឿលើព្រះគម្ពីរនិងដំណឹងល្អទេ នោះកម្មវិធីសរសើរនិងលើកទឹកចិត្តនោះប្រហែលជាមិនមានគ្រីស្ទបរិស័ទអធិប្បាយព្រះបន្ទូលនោះទេ ហើយខ្ញុំក៏មិនស្មានថាយើងនឹងមានសេចក្តីអធិប្បាយមួយនៅពេលកូនប្រុសរបស់ខ្ញុំទទួលសញ្ញាប័ត្រនោះដែរ។ គេបានអញ្ជើញគ្រូជនជាតិយូដាម្នាក់ដែលខ្ញុំបានស្គាល់ទៅអធិប្បាយ។ គាត់ឆ្លាត គួរឲ្យចាប់ចិត្ត និងគួរឲ្យចាប់អារម្មណ៍ ដូច្នេះខ្ញុំមិនភ្ញាក់ផ្អើលដែលការអធិប្បាយរបស់គាត់បានលើកទឹកចិត្ត មានការអនុវត្ត និងពេញដោយគំនិត។ ការពិត វាជាសេចក្តីអធិប្បាយល្អបំផុតដែលខ្ញុំចងចាំ ខ្ញុំបានយល់ស្របជាមួយនឹងគ្រប់យ៉ាងដែលគាត់បាននិយាយដោយគ្មានការលើកលែង។

នៅពេលកូនប្រុសម្នាក់របស់ខ្ញុំបានបញ្ចប់ការសិក្សានិងទទួលសញ្ញាប័ត្រមហាវិទ្យាល័យរបស់គាត់តែងតែប្រារព្ធធ្វើកម្មវិធីមួយដើម្បីសរសើរនិងលើកទឹកចិត្តដល់ថ្នាក់ដែលត្រូវទទួលសញ្ញាប័ត្រ។ ជាប្រវត្តិសាស្ត្រ កម្មវិធីទាំងនេះត្រូវបានបង្កើតឡើងប្រយោជន៍ដើម្បីអោយអ្នកបម្រើដំណឹងល្អមានឱកាសចែកចាយសេចក្តីអធិប្បាយ។ ប៉ុន្តែសព្វថ្ងៃនេះបើសិនស្ថាប័នសិក្សាអប់រំមិនជឿលើព្រះគម្ពីរនិងដំណឹងល្អទេ នោះកម្មវិធីសរសើរនិងលើកទឹកចិត្តនោះប្រហែលជាមិនមានគ្រីស្ទបរិស័ទអធិប្បាយព្រះបន្ទូលនោះទេ ហើយខ្ញុំក៏មិនស្មានថាយើងនឹងមានសេចក្តីអធិប្បាយមួយនៅពេលកូនប្រុសរបស់ខ្ញុំទទួលសញ្ញាប័ត្រនោះដែរ។ គេបានអញ្ជើញគ្រូជនជាតិយូដាម្នាក់ដែលខ្ញុំបានស្គាល់ទៅអធិប្បាយ។ គាត់ឆ្លាត គួរឲ្យចាប់ចិត្ត និងគួរឲ្យចាប់អារម្មណ៍ ដូច្នេះខ្ញុំមិនភ្ញាក់ផ្អើលដែលការអធិប្បាយរបស់គាត់បានលើកទឹកចិត្ត មានការអនុវត្ត និងពេញដោយគំនិត។ ការពិត វាជាសេចក្តីអធិប្បាយល្អបំផុតដែលខ្ញុំចងចាំ ខ្ញុំបានយល់ស្របជាមួយនឹងគ្រប់យ៉ាងដែលគាត់បាននិយាយដោយគ្មានការលើកលែង។

បន្ទាប់ពីខ្ញុំបានស្តាប់សេចក្តីអធិប្បាយនោះ ខ្ញុំបានសញ្ជឹងគិតអំពីលក្ខណៈនៃការអធិប្បាយរបស់គ្រីស្ទបរិស័ទសព្វថ្ងៃនេះ។ វាជាទូទៅមានការចាប់អារម្មណ៍តិចជាងការអធិប្បាយរបស់គ្រូសាសនាយូដា ហើយជារឿយៗការអធិប្បាយរបស់គ្រីស្ទបរិស័ទមិនមានអ្វីដែលគ្រូសាសនាយូដានឹងមិនយល់ស្របនោះទេ។ គួរឲ្យសោកស្តាយមានសេចក្តីអធិប្បាយជាច្រើនដែលបានអធិប្បាយតាមទូរទស្សន៍ តាមវិទ្យុនិងអាសនាក្នុងព្រះវិហារមិនមានអ្វីជាគ្រីស្ទ

បរិស័ទច្បាស់លាស់នោះទេ។ សេចក្ដីអធិប្បាយទាំងនោះតែមាន “សុភវិនិច្ឆ័យ ឬ ភាពឈ្លៀសវៃ” ដែលជាទូទៅមនុស្សមានឆន្ទៈល្អយល់ស្របជាមួយ។ ជារឿយៗយើងផ្ដល់ប្រាជ្ញាអនុវត្តដដែលៗដែលអ្នកដទៃទៀតផ្ដល់ឲ្យដែរ ប៉ុន្ដែយើងសំដៅទៅលើរឿងក្នុងព្រះគម្ពីរឬលើសេចក្ដីពិតរបស់ព្រះគម្ពីរផងដែរ។ មិត្តរបស់ខ្ញុំដែលជាគ្រូសាសនាយូដាក៏ប្រើរឿងនិងគោលការណ៍ចេញពីព្រះគម្ពីរសញ្ញាចាស់និងថ្មីផងដែរ ហើយគាត់ធ្វើការនេះបានយ៉ាងល្អ។ ដូច្នេះ តើការអធិប្បាយរបស់គ្រីស្ទបរិស័ទគួរតែមានអ្វីដែលខុសពីគេ?

ព្រះយេស៊ូវគ្រីស្ទនិងអ្វីដែលទ្រង់បានធ្វើដើម្បីប្រោសលោះរាស្ដ្ររបស់ទ្រង់ គឺជាគ្រឹះក្នុងការអធិប្បាយរបស់គ្រីស្ទបរិស័ទ។ ដំណឹងល្អប្រកាសអំពីទ្រង់។ ដំណឹងល្អថ្វាយសិរីល្អដល់ព្រះវរបិតាដោយការថ្វាយសិរីល្អដល់ព្រះគ្រីស្ទ។ ប្រសិនបើយើងយល់ខុសឬកាត់ស្រាយខុសថាព្រះគ្រីស្ទជាអ្នកណានិងថាអ្វីដែលព្រះគ្រីស្ទបានធ្វើ នោះយើងធ្វើឲ្យសេចក្ដីសង្គ្រោះដ៏អស់កល្បរបស់យើងមានគ្រោះថ្នាក់ហើយ។ ដូច្នេះ នៅចំនុចកណ្ដាលនៃសេចក្ដីថ្លែងអំពីសេចក្ដីជំនឿក្រុមចម្រុះដំណឹងល្អគឺជាការប្រកាសទាក់ទងនឹងព្រះយេស៊ូវគ្រីស្ទនិងការងារប្រោសលោះដ៏អស្ចារ្យរបស់ទ្រង់។ នេះគឺជាចំនុចកណ្ដាលនៃអ្វីដែលយើងបង្រៀននិងអធិប្បាយ។

## ព្រះគ្រីស្ទជាព្រះរាជបុត្រាដ៏អស់កល្ប

“យើងជឿថា ដោយសារសេចក្ដីស្រឡាញ់និងការស្ដាប់បង្គាប់ចំពោះព្រះវរបិតា...”។[១] តាំងពីដើម សេចក្ដីថ្លែងអំពីសេចក្ដីជំនឿរបស់យើងឆ្លើយ

សំនួរនេះ “តើហេតុអ្វីព្រះយេស៊ូវគ្រីស្ទធ្វើអ្វីដែលទ្រង់បានធ្វើ?” មានតែការពន្យល់មួយដែលយើងរៀនបានពីព្រះគម្ពីរគឺ ព្រះយេស៊ូវគ្រីស្ទស្រឡាញ់យើង មិនមែនដោយសារយើងជាអ្នកណាទេ តែដោយសារទ្រង់ជាអ្នកណាវិញ។ ក្រៅពីសេចក្ដីស្រឡាញ់ នោះយើងមិនអាចយល់អំពីព្រះយេស៊ូវគ្រីស្ទបានឡើយ។ សេចក្ដីស្រឡាញ់ជំរុញឲ្យទ្រង់ធ្វើអ្វីៗទាំងអស់ដែលទ្រង់បានធ្វើ។ ប្រសិនបើយើងមិនអាចទទួលយកសេចក្ដីស្រឡាញ់ នោះយើងក៏មិនអាចទទួលយកព្រះគ្រីស្ទបានដែរ។ ប្រសិនបើយើងមិនអាចផ្ដល់សេចក្ដីស្រឡាញ់ នោះយើងក៏មិនអាចបម្រើព្រះគ្រីស្ទបានដែរ។ សេចក្ដីជំរុញដ៏ប្រសើរពីខាងក្រោយគ្រប់ទាំងព្រះបន្ទូលនិងការទង្វើរបស់ទ្រង់ ហើយពីខាងក្រោយការលះបង់ដ៏ធំធេងរបស់ទ្រង់សម្រាប់យើង គឺជាសេចក្ដីស្រឡាញ់របស់ទ្រង់ដែលយើងមិនសមនឹងទទួល។

អ្វីដែលធ្វើឲ្យសេចក្ដីស្រឡាញ់នេះកាន់តែអស្ចារ្យនោះគឺថា នៅមុនព្រះយេស៊ូវគ្រីស្ទបានយាងមកផែនដី ទ្រង់បានគង់នៅជាអង្គបុគ្គលទីពីរនៃភាពជាព្រះអម្ចាស់ ជាព្រះរាជបុត្រាដ៏អស់កល្បជានិច្ចរបស់ព្រះ។ យ៉ូហានសរសេរថា “កាលដើមដំបូងមានព្រះបន្ទូល ព្រះបន្ទូលក៏គង់នៅជាមួយនឹងព្រះ ហើយព្រះបន្ទូលនោះឯងជាព្រះ” (យ៉ូហាន ១:១)។ យ៉ូហានក៏ហៅទ្រង់ថា “ព្រះរាជបុត្រាតែមួយ” (យ៉ូហាន ១:១៤)។[២] ទ្រង់ “បានគង់នៅមុនអស់ទាំងលោកិយ ជាព្រះនៃព្រះ ជាពន្លឺនៃពន្លឺ” (គោលជំនឿណាយសៀ Nicene Creed)។ ទ្រង់មានអំណរបរិសុទ្ធតាំងពីអស់កល្ប មានភាពស្មើនឹងព្រះវរបិតានិងព្រះវិញ្ញាណបរិសុទ្ធ។ ទ្រង់មិនត្រូវការមិត្តភ័ក្ដិព្រោះទ្រង់មានទំនាក់ទំនង

យ៉ាងជិតស្និទ្ធនិងស្តាប់ព្រះទ័យជាមួយព្រះវរបិតាហើយមានអស់ទាំងសេចក្តីរីករាយដ៏អស់កល្បជានិច្ច។

សេចក្តីស្រឡាញ់ដែលជំរុញឲ្យទ្រង់លះចោលពីបរិយាកាសដែលមានពររបស់ទ្រង់ហើយយាងមកផែនដីនេះគឺជាសេចក្តីស្រឡាញ់របស់ទ្រង់សម្រាប់យើង ដូចជាព្រះវរបិតារបស់ទ្រង់ស្រឡាញ់យើងដែរ! ព្រះយេស៊ូវបានមានបន្ទូលថា ទ្រង់បានយាងមកធ្វើតាមបំណងព្រះហឫទ័យរបស់ព្រះវរបិតាទ្រង់ ហើយបំណងព្រះហឫទ័យរបស់ព្រះវរបិតាទ្រង់គឺថា រាស្ត្ររបស់ទ្រង់បានសង្គ្រោះ។ ព្រះរាជបុត្រានៃព្រះមានចំណែកទាំងស្រុងនៅក្នុងបំណងព្រះហឫទ័យដោយសេចក្តីស្រលាញ់នោះ ដែលជាសេចក្តីស្រឡាញ់ដ៏បរិសុទ្ធ ហើយពេញដោយព្រះគុណដែលមនុស្សនិងទេវតាមិនអាចយល់បាន។

## ព្រះគ្រីស្ទជាព្រះអង្គសង្គ្រោះរបស់យើងដែលបន្ទាបខ្លួន

**“ព្រះរាជបុត្រាដែលគង់នៅអស់កល្បជានិច្ចបានយកកំណើតជាមនុស្ស”**

លក្ខណៈគួរឲ្យកត់សម្គាល់មួយរបស់ព្រះយេស៊ូវគ្រីស្ទគឺការបន្ទាបខ្លួនរបស់ទ្រង់។ យើងមិនអាចយល់អំពីជម្រៅនៃការបន្ទាបខ្លួនដែលបានតម្រូវឲ្យលះចោលបល្ល័ង្កស្ថានសួគ៌មកកើតជាមនុស្សនៅលើផែនដីជាមួយស្ត្រីអ្នកស្រែចំការម្នាក់បាននោះឡើយ។ គេបាននិពន្ធកំណាព្យនិងបទចម្រៀងសរសើរតម្កើងរាប់ពាន់ក្នុងគោលបំណងបរិយាយអំពីសេចក្តីពិតដ៏អស្ចារ្យនេះ។

ព្រះអង្គដែលមានលើសអស់ទាំងភាពរុងរឿង
ដោយសារសេចក្តីស្រលាញ់ទ្រង់បានត្រឡប់ជាក្រ

ទ្រង់បានលះចោលបល្ល័ង្ករបស់ទ្រង់មកឯស្នូកសត្វ
ទ្រង់បានលះចោលព្រះរាជវាំងក្រាលដោយត្បូងកណ្តៀង មកឯក្រោល
ព្រះអង្គដែលមានលើសអស់ទាំងភាពរុងរឿង
គ្រប់ទាំងអស់ដោយសារសេចក្តីស្រឡាញ់ បានត្រឡប់ជាក្រ។[៣]

ប៉ុលចូលរួមច្រៀងថា «ទោះបើទ្រង់មានរូបអង្គជាព្រះ ក៏ដោយ គង់តែមិនបានរាប់សេចក្តីដែលស្មើនឹងព្រះនោះ ទុកជាសេចក្តីដែលគួរកាន់ខ្ជាប់ឡើយ គឺទ្រង់បានលះបង់ព្រះអង្គទ្រង់ មកយករូបភាពជាបាវបម្រើវិញ ព្រមទាំងប្រសូតមកមានរូបភាពជាមនុស្សផង ហើយដែលឃើញទ្រង់មានភាពជាមនុស្សដូច្នោះ នោះក៏បន្ទាបព្រះអង្គទ្រង់ ទាំងចុះចូលស្តាប់បង្គាប់ រហូតដល់ទីមរណៈ គឺទ្រង់ទទួលសុគតជាប់លើឈើឆ្កាងផង» (ភីលីព ២:៦-៨)។

ការបន្ទាបខ្លួននេះចាំបាច់សម្រាប់មនុស្សជាតិដើម្បីបានសង្គ្រោះចេញពីស្ថានភាពរបស់យើង។ យើងមិនបានសង្គ្រោះចេញស្ថានភាពរបស់យើងដោយការខិតខំរបស់មនុស្សបាននោះទេ។ អ្វីដែលព្រះយេស៊ូវបានធ្វើសម្រាប់យើង នោះយើងមិនអាចធ្វើសម្រាប់ខ្លួនយើងបានឡើយ។ ផ្លូវតែមួយដែលយើងអាចបានសង្គ្រោះគឺ ដោយព្រះយាងចុះមកស្ថានភាពលំបាករបស់យើងនៅក្នុងលោកិយដែលធ្លាក់ចុះនេះ។ ទ្រង់ត្រូវតែយាងមកហើយទទួលយកយើង ហើយនេះពិតជាអ្វីដែលទ្រង់បានធ្វើ។

យើងបែងចែកជីវិតរបស់ព្រះយេស៊ូវជាពីរផ្នែកតាមប្រវត្តិសាស្ត្រ ការបន្ទាបខ្លួនរបស់ទ្រង់ និងការតម្កើងឡើងរបស់ទ្រង់។ នៅពេលយើងនិយាយអំពីការបន្ទាបខ្លួនរបស់ទ្រង់ ធម្មតាយើងរួមបញ្ចូលទាំងការយកនិស្ស័យជាមនុស្សរបស់

ទ្រង់ ការចុះចូលទាំងស្រុងរបស់ទ្រង់ចំពោះក្រឹត្យវិន័យរបស់ព្រះ ហើយការរងទុក្ខ ការសុគត និងការបញ្ចុះក្នុងផ្នូររបស់ទ្រង់។ អ្នកអាចឃើញការនេះនៅក្នុងសេចក្តីថ្លែងអំពីសេចក្តីជំនឿរបស់យើង។ ចំនុចនីមួយៗនៃការបន្ទាបខ្លួនរបស់ទ្រង់សំខាន់សម្រាប់សេចក្តីប្រោសលោះរបស់រាស្ត្ររបស់ព្រះ ដូច្នេះហើយវាជាការត្រឹមត្រូវនិងល្អសម្រាប់យើងជឿលើការទាំងនេះ  សញ្ជឹងគិតលើការទាំងនេះ អបអរសាទរការទាំងនេះ ហើយរស់នៅដោយការអនុវត្តការទាំងនេះ។

## *ការយកនិស្ស័យជាមនុស្សរបស់ទ្រង់*

“ព្រះបន្ទូលបានត្រឡប់ជាសាច់ឈាមជាព្រះពេញលេញជាមនុស្សជាតិពេញលេញគឺបុគ្គលម្នាក់ដែលមាននិស្ស័យពីរ។ មនុស្សឈ្មោះយេស៊ូវដែលជាព្រះមែស៊ីនៃសាសន៍អ៊ីស្រាអែលដែលព្រះបានសន្យាថានឹងយាងមកទ្រង់បានចាប់កំណើតតាមរយៈការចាប់ទំផ្ទៃដ៏អស្ចារ្យគឺព្រះវិញ្ញាណបរិសុទ្ធហើយក៏ប្រសូតមកពីក្រមុំព្រហ្មចារីឈ្មោះនាងម៉ារា»។  ការចាប់កំណើតនិងការប្រសូតមករបស់ព្រះយេស៊ូវមិនគ្រាន់តែការមិនធម្មតានិងអស្ចារ្យប៉ុណ្ណោះទេ ប៉ុន្តែវាពិសេសដាច់ដោយឡែក។ នៅក្នុងព្រះគម្ពីរសញ្ញាចាស់មានការចាប់កំណើតនិងការកើតមិនធម្មតាខ្លះ ដូចជាអ័ប្រាហាំ (អាយុកៅសិបប្រាំបួនឆ្នាំ) និងសារ៉ា (អាយុកៅសិបឆ្នាំ) ផ្តល់កំណើតដល់អ៊ីសាក។ ក៏មានការចាប់កំណើតពិសេសរបស់សាំយូអែល (១សាំយូអែល ១) សាំសុន (ចៅហ្វាយ ១៣) និងយ៉ូហានបាទីស្ទ (លូកា ១) ប៉ុន្តែការកើតមកទាំងនេះក៏ដូចជាការកើតមកផ្សេងៗទៀតដែលធ្លាប់កើតមាន បានពាក់ព័ន្ធនឹងឪពុកម្តាយជាមនុស្ស។

មានតែក្នុងករណីរបស់ព្រះយេស៊ូវពីភូមិណាសារ៉ែតប៉ុណ្ណោះគឺជាមនុស្សជាតិដែលបានចាប់កំណើតនិងបានប្រសូត្រមកពីម្តាយនិងព្រះ។ អស់ជាច្រើនឆ្នាំ ហើយសូម្បីតែសព្វថ្ងៃ អ្នកខ្លះបាននិយាយថា សេចក្តីពិតដែលថាការប្រសូត្រមកតាមស្ត្រីក្រមុំព្រហ្មចារីគឺល្អ ប៉ុន្តែមិនចាំបាច់ គឺជារឿងដែលយើងមិនគួរឈ្លោះគ្នានោះទេ។ ផ្ទុយទៅវិញ អ្នកទេវសាស្ត្រដ៏អស្ចារ្យ លោកអាថាន់ណាសៀស Athanasius (២៩៦-៣៧៣ គ.ស) បានបង្រៀនថាព្រះគ្រីស្ទចាំបាច់ត្រូវមកជាមនុស្សពេញលេញ ពីព្រោះព្រះអាចសង្គ្រោះតែអ្វីដែលព្រះគ្រីស្ទបានត្រឡប់មកជាប៉ុណ្ណោះ ដូច្នេះប្រសិនបើព្រះគ្រីស្ទមិនមែនជាមនុស្សពេញលេញនោះទេ មនុស្សមិនអាចបានសង្គ្រោះពេញលេញផងដែរ។ លោក អាន់សែម Anselm (១០៣៣-១១០៩) បានបង្រៀនថាព្រះគ្រីស្ទត្រូវតែជាព្រះពេញលេញដើម្បីឲ្យយញ្ញបូជារបស់ទ្រង់គ្រប់គ្រាន់សម្រាប់រាស្ត្រទាំងអស់របស់ព្រះ បើមិនដូច្នេះ ព្រះគ្រីស្ទគ្រាន់តែជាមនុស្សម្នាក់ប៉ុណ្ណោះ ហើយមនុស្សម្នាក់មិនអាចជំនួសលើសជាងមនុស្សម្នាក់ទៀតនោះឡើយ។

យើងនៅតែជឿការនេះនៅសព្វថ្ងៃ មិនមែនដោយសារតែលោក អានសែម និងលោក អាថាន់ណាសៀស បានបង្រៀនវានោះទេ ប៉ុន្តែដោយសារតែការសរសេររបស់ម៉ាថាយនិងលូកា(ដែលបណ្តាលដោយព្រះ) បង្រៀនសេចក្តីពិតនេះ (ម៉ាថាយ ១ លូកា ១-២)។ តើយើងអាចយល់អំពីជម្រៅនៃការបន្ទាបខ្លួនរបស់ព្រះគ្រីស្ទនៅក្នុងការយកនិស្ស័យជាមនុស្សបានដោយរបៀបណា? បើសិនប៊ីល និងមេលីនដា ហ្គេត ដែលជាមហាសេដ្ឋីពិភពលោកបានចាកចេញ

ពីព្រះរាជវាំងរបស់ពួកគេ ហើយបានរស់នៅកណ្ដាលតំបន់ក្រីក្រ Kibera នៅ Nairobi ប្រទេស Kenya នោះសកម្មភាពនោះនៅតែមិនស្មើនឹងកំរិតនៃការដែលព្រះយេស៊ូវបានទ្រាំទ្រធ្វើជាមនុស្សនោះទេ។ ព្រះអង្គជាព្រះអង្គសង្គ្រោះដ៏មានសេចក្ដីស្រឡាញ់ម្ល៉េះហ្ន៎!

## *ការចុះចូលទាំងស្រុងរបស់ទ្រង់ចំពោះព្រះវរបិតា*

"ទ្រង់បានស្ដាប់បង្គាប់យ៉ាងគ្រប់លក្ខណ៍ដល់ព្រះវរបិតាទ្រង់ដែលគង់នៅស្ថានសួគ៌បានរស់នៅជីវិតដែលគ្មានបាបសោះបានធ្វើទីសំគាល់អស្ចារ្យជាច្រើន"។ មិនសូវយូរប៉ុន្មានកន្លងទៅ ព្រះវិហាររបស់ខ្ញុំឈ្មោះថា ព្រិសបេធើរានទីពីរ (2nd Presbyterian) នៅក្នុង Memphis, Tennessee បានផ្ដល់ឲ្យប្រពន្ធខ្ញុំនិងខ្ញុំនូវពេលវេលាសំរាកមួយ ហើយបានចំណាយបួនសប្ដាហ៍ធ្វើដំណើរជុំវិញ។ រៀងរាល់ថ្ងៃអាទិត្យយើងបានទៅពួកជំនុំផ្សេងៗគ្នា ហើយយើងបានភ្ញាក់ផ្អើលពេលឮពួកគ្រូអធិប្បាយ ដែលនៅឆ្ងាយពីគ្នារាប់រយគីឡូម៉ែត្រ ធ្វើការសូមទោសដល់ក្រុមជំនុំរបស់ពួកគេ ពីរអាទិត្យជាប់គ្នាសម្រាប់ការមិនអត់ធ្មត់ ភាពឆេវឆាវ និងភាពគ្មានសេចក្ដីមេត្តារបស់ព្រះគ្រីស្ទ។ ខ្ញុំស្ទើរតែមិនជឿអ្វីដែលខ្ញុំបានកំពុងស្ដាប់ឮទេ។ តើពួកគេយល់អំពីការអនុវត្តដែលមកពីគោលលទ្ធិខុសឆ្គងរបស់ពួកគេដែរឬទេ? តើពួកគេដឹងថា បើសិនព្រះគ្រីស្ទជាអ្នកមានបាបម្នាក់ក្នុងកម្រិតណាក៏ដោយ នោះទ្រង់ជាយញ្ញបូជា "ដែលប្រមាថ" មិនសមនឹងធួនសម្រាប់អំពើបាបរបស់យើងដែរឬទេ?

ប៉ុន្តែសូមសរសើរតម្កើងព្រះអង្គ ព្រះគម្ពីរប្រកាសថា ទ្រង់គឺយញ្ញបូជា

ដ៏មានតំលៃមួយសម្រាប់យើង ពីព្រោះទ្រង់មិនដែលធ្វើបាបនៅក្នុងគំនិត ពាក្យសម្ដី ឬការប្រព្រឹត្ត បើទោះទ្រង់ត្រូវល្បួងដូចយើងគ្រប់យ៉ាងទាំងអស់ក៏ដោយ។ មិនត្រឹមតែជីវិតរបស់ទ្រង់ជាយញ្ញបូជាមួយដែលព្រះវរបិតាអាចទទួលបានសម្រាប់អំពើបាបរបស់យើងនោះទេ ប៉ុន្តែព្រះគម្ពីរបង្រៀនផងដែរថា ទ្រង់សព្វព្រះទ័យដាក់អង្គទ្រង់នៅក្រោមអំណាចក្រឹត្យវិន័យដើម្បីឲ្យទ្រង់អាចសម្រេចបានឲ្យយើងទាំងអស់គ្នានូវអ្វីដែលឪពុកដំបូងរបស់យើង អ័ដាម បានបរាជ័យធ្វើ។ ព្រះយេស៊ូវបាន «មកចាប់កំណើតនឹងស្ត្រី...ក្រោមអំណាចនៃក្រឹត្យវិន័យ» (កាឡាទី ៤:៤-៧) បានកាត់ស្បែក (លូកា ២) មានឪពុកម្ដាយ (លូកា ២) ហើយបានទទួលបុណ្យជ្រមុជទឹកដោយយ៉ូហានបាទីស្ទ (យ៉ូហាន ១) ដើម្បីបំពេញសម្រេចសេចក្ដីសុចរិតទាំងអស់ជំនួសយើង។

## *ការរងទុក្ខ ការសុគត និងការបញ្ចុះក្នុងផ្នូររបស់ទ្រង់*

«**បានជាប់ឆ្កាងនៅក្រោមអំណាចប៉ុនទាសពីឡាត់**» ព្រះយេស៊ូវបានរងទុក្ខជាច្រើននៅកំឡុងពេលបីឆ្នាំនៃព័ន្ធកិច្ចជាសាធារណៈរបស់ទ្រង់ ការទាមទាររបស់អ្នកក្រីក្រ អ្នកពិការអ្នកទុរគត ការស្អប់ខ្ពើមពីពួកអ្នកដឹកនាំសាសនា ការមិនជឿរបស់ពួកសិស្សរបស់ទ្រង់ផ្ទាល់ និងភាពឃោរឃៅរបស់ពួករ៉ូម៉ាំងនៅក្នុងអ៊ីស្រាអែល។ ប៉ុន្តែការរងទុក្ខដ៏ធំបំផុតបានមកពីព្រះវរបិតារបស់ទ្រង់ផ្ទាល់។ នៅយប់មុនការជាប់ឆ្កាងរបស់ទ្រង់ក្នុងសួនច្បារគែតសេម៉ានី ទ្រង់បានអធិស្ឋានដោយតប់ប្រមល់យ៉ាងខ្លាំងថា «ឱព្រះវរបិតាអើយ បើសិនជាទ្រង់សព្វព្រះហឫទ័យ នោះសូមយកពែងនេះចេញពីទូលបង្គំទៅ ប៉ុន្តែ កុំតាម

ចិត្តទូលបង្គំឡើយ សូមតាមតែព្រះហឫទ័យទ្រង់វិញ» (លូកា ២២:៤២)។ បន្ទាប់មកពីលើឈើឆ្កាងក្នុងការបំពេញសម្រេចទំនុកដំកើងអំពីព្រះមែស៊ី (ទំនុកដំកើង ២២) ព្រះយេស៊ូវបានពន្លឺសំឡេងជាខ្លាំងទៅកាន់ព្រះវរបិតាទ្រង់ថា «ឱព្រះអង្គៗនៃទូលបង្គំអើយ ហេតុអ្វីបានជាទ្រង់ចោលទូលបង្គំ?» (ម៉ាថាយ ២៧:៤៦)។

ហេតុអ្វីបានជាព្រះអនុញ្ញាតឬកំណត់ជាមុនឲ្យមានការអយុត្តិធម៌ដូចនេះ? (កិច្ចការ ២:២២-២៣)។ គម្ពីរកូរ៉ានបង្រៀនចម្លើយមួយចំពោះសំនួរនេះថា ព្រះយេស៊ូវពិតជាមិនបានសុគតនោះទេ។ គឺជាមនុស្សម្នាក់ផ្សេងទៀតដែលបានស្លាប់ (យូដាស) ដែលគ្រាន់តែមើលដូចជាព្រះយេស៊ូវប៉ុណ្ណោះ។ គម្ពីរកូរ៉ានបង្រៀនថា ហោរាសុចរិតដូចជាព្រះយេស៊ូវមិនអាចត្រូវគេបង្អាប់បន្ថោកបានទេ គឺព្រះមិនអនុញ្ញាតនោះឡើយ។ ប៉ុន្តែអស្ចារ្យខ្លាំងណាស់ ព្រះមិនគ្រាន់តែអនុញ្ញាតការសុគតនេះ ប៉ុន្តែការនេះជាផែនការណ៍របស់ព្រះអង្គចាប់តាំងពីអស់កល្បជានិច្ចមក (១ពេត្រុស ១:១៩-២០)។ ដោយសារទ្រង់ស្រឡាញ់យើង ព្រះយេស៊ូវបានរងទុក្ខការថោកទាបបំផុតនៃការត្រូវគេវាយដំនិងឆ្កាងដូចជាឧក្រិដ្ឋជនធម្មតាដែរ។ នេះជាសេចក្តីស្រឡាញ់ដ៏អស្ចារ្យ!

## ព្រះគ្រីស្ទជាព្រះអម្ចាស់ដែលបានលើកតម្កើង

យើងគ្រាន់តែអាចស្រមើស្រមៃអំពីការអស់សង្ឃឹមស្ងៀមស្ងាត់របស់ពួកសិស្សនៅថ្ងៃសៅរ៍បន្ទាប់ពីការជាប់ឆ្កាងរបស់ព្រះយេស៊ូវ។ ពួកគេបានជឿថា ទ្រង់គឺជាព្រះមែស៊ីដែលពួកគេបានរង់ចាំជាយូរមកហើយ។ ប៉ុន្តែគ្រប់គ្នាដឹងថា តួនាទី

របស់ព្រះមែស៊ីគឺគ្រប់គ្រង ហើយប្រយោជន៍ដើម្បីអោយសោយរាជ្យ ពួកគេត្រូវតែនៅរស់។ ប៉ុន្តែគេឃើញថា ព្រះយេស៊ូវបានសុគតហើយ។ ការសុគតរបស់ទ្រង់ផ្ទុយនឹងអ្វីដែលពួកគេបានស្ដាប់ឮនិងឃើញនៅក្នុងទ្រង់អស់រយៈពេលបីឆ្នាំដែលពួកគេបានរួមដំណើរជាមួយទ្រង់។

ពួកគេបានបម្រើជាមួយទ្រង់ បានបរិភោគជាមួយទ្រង់ បានគេងជាមួយទ្រង់ ហើយបានអធិស្ឋានជាមួយទ្រង់ ហើយពួកគេមិនដែលបានស្ដាប់ឮពាក្យសម្ដីដែលមានបាប មិនដែលបានឃើញឥរិយាបថមិនល្អ ឬមិនដែលបានឃើញការខ្វះសេចក្ដីស្រឡាញ់ចំពោះអ្នកខ្វះខាត ហើយពួកគេមិនដែលបានឃើញថាទ្រង់បានចាញ់ពួកបព្វជិតនិងពួកអ្នកប្រាជ្ញនោះឡើយ។ ពួកគេបានឃើញទ្រង់ធ្វើឲ្យខ្យល់និងរលកស្ងប់ បណ្ដេញអារក្ស ព្យាបាលមនុស្សខ្វាក់ ហើយប្រោសមនុស្សស្លាប់ឲ្យរស់ឡើងវិញ។ ពួកគេបានហៅទ្រង់ថា “ព្រះគ្រីស្ទ” ហើយទ្រង់បានធានាពួកគេថា ព្រះវិញ្ញាណបរិសុទ្ធបានបើកសំដែងសេចក្ដីពិតនោះទៅកាន់ពួកគេ។ គ្រប់យ៉ាងចង្អុលថា ទ្រង់ជាព្រះមែស៊ី។ តើទ្រង់អាចបានសុគតយ៉ាងម៉េចទៅ?

នៅព្រឹកថ្ងៃអាទិត្យបន្ទាប់ពីការជាប់ឆ្កាងនៅថ្ងៃសុក្ររបស់ទ្រង់ ស្ត្រីខ្លះបានយកគ្រឿងក្រអូបទៅឯផ្នូររបស់ព្រះយេស៊ូវដើម្បីថែរក្សានិងគោរពសពរបស់ទ្រង់។ ពួកគេបានក្លាយជាសាក្សីជាមនុស្សដំបូងចំពោះការ អស្ចារ្យធំបំផុត។ ព្រះយេស៊ូវបានសុគតហើយ ប៉ុន្តែឥឡូវនេះទ្រង់នៅរស់! អ្វីដែលពួកអ្នកទេវសាស្ត្រហៅថា ការលើកតម្កើងរបស់ព្រះគ្រីស្ទបានចាប់ផ្ដើមហើយ។ ការលើកតម្កើងរបស់ព្រះគ្រីស្ទមានការរស់ឡើងវិញពីសុគតរបស់

ទ្រង់ ការយាងត្រឡប់ទៅវិញរបស់ទ្រង់ ការអង្គុយនៅខាងស្តាំដៃព្រះវរបិតា និងការយាងត្រឡប់មកវិញដ៏មានសិរីល្អរបស់ទ្រង់។

## *ការរស់ពីសុគតឡើងវិញរបស់ទ្រង់*

**"លុះដល់ថ្ងៃទីបីសពទ្រង់ក៏បានរស់ពីសុគតឡើងវិញ"** ការរស់ឡើងវិញពីសុគតរបស់ព្រះយេស៊ូវគ្រីស្ទគឺជាព្រឹត្តិការណ៍ធំបំផុតនៃការងារប្រោសលោះដ៏វិសេសវិសាលរបស់ព្រះ គឺវិសេសវិសាលជាងការញែកទឹកសមុទ្រ ឬការធ្វើឲ្យភ្នំស៊ីណាយរញ្ជួយ ឬការបាក់រលំរបស់កំផែងក្រុងយេរីខូរ ឬជ័យជំនះរបស់ដាវីឌលើកូលីយ៉ាតទៅទៀត។ អនាគតរបស់ស្ថានព្រះហស្តអាស្រ័យលើសកម្មភាពដ៏អស្ចារ្យរបស់ព្រះនេះ(គឺការរស់ឡើងវិញរបស់ព្រះគ្រីស្ទ)។ សេចក្តីសង្ឃឹមរបស់អ្នកជឿនិមួយៗអាស្រ័យទាំងស្រុងលើសេចក្តីពិតនៃព្រឹត្តិការណ៍ប្រវត្តិសាស្ត្រនេះ។

ការរស់ពីសុគតឡើងវិញរបស់ព្រះគ្រីស្ទមិនដូចជា(ដូចជាអ្នកខ្លះអះអាង) គ្រាន់តែជាគំនិតមួយដែល មិនមែនជា "ការរស់ឡើងវិញខាងវិញ្ញាណ" ប៉ុណ្ណោះទេ ប៉ុន្តែជាការរស់ឡើងវិញខាងរូបកាយដែលបានឈឺចាប់និងសុគតនៅលើឈើឆ្កាងផងដែរ។ នេះគឺជាអ្វីដែលពួកសិស្សដំបូងបានប្រកាសយ៉ាងមានអំណាចយ៉ាងក្លាហាន និងឥតឈប់ឈរថា "ព្រះទ្រង់បានលើកព្រះយេស៊ូវនេះ ដែលអ្នករាល់គ្នាបានឆ្កាង ឲ្យទ្រង់ធ្វើជាព្រះអម្ចាស់ ហើយជាព្រះគ្រីស្ទផង" (កិច្ចការ ២:៣៦)។ ពួកសិស្សបានមានអំណរក្រៃលែងពីព្រោះព្រះអម្ចាស់របស់ពួកគេត្រូវបានដោះរួចទោសពិតហើយបានលើកតម្កើងយ៉ាងខ្ពស់បំផុត

“តែខាងឯព្រះវិញ្ញាណនៃសេចក្ដីបរិសុទ្ធ នោះបានសំដែងមកច្បាស់ថា ទ្រង់ជាព្រះរាជបុត្រារបស់ព្រះពិត ទាំងមានព្រះចេស្ដាផង ដោយទ្រង់បានរស់ពីស្លាប់ឡើងវិញ គឺជាព្រះយេស៊ូវគ្រីស្ទ ជាព្រះអម្ចាស់នៃយើងរាល់គ្នា” (រ៉ូម ១:៤)។

## *ការលើកឡើងទៅស្ថានសួគ៌របស់ទ្រង់*

**“ហើយក៏បានយាងទៅឯស្ថានសួគ៌វិញ”។** ពួកសិស្សមានអំណរមិនគ្រាន់តែដោយសារព្រះយេស៊ូវនៅរស់ប៉ុណ្ណោះទេ ប៉ុន្តែក៏ដោយសារពួកគេបានមើលឃើញទ្រង់យាងទៅស្ថានសួគ៌វិញផងដែរ (លូកា ២៤ កិច្ចការ ១)។ ទ្រង់បានយកឈ្នះលើអស់ទាំងពួកខ្មាំងសត្រូវរបស់ទ្រង់និងរបស់យើងដោយឈើឆ្កាងនឹងការរស់ឡើយវិញរបស់ទ្រង់ ហើយនៅចំពោះមុខពួកសិស្ស ទ្រង់យាងត្រឡប់ទៅស្ថានសួគ៌វិញក្នុងនាមជាស្ដេច។ ទ្រង់លែងនៅក្រោមគម្រោងការអាក្រក់របស់ពួកផារីស៊ី គម្រោងការអាក្រក់របស់ពួកសាឌូស៊ី ឬភាពសាហាវឃោរឃៅរបស់ពួករ៉ូមម៉ាំងទៀតហើយ។ កែផាស ពីឡាត់ និងបាវព្រាវរបស់ពួកគេ ឬសាតាំងផ្ទាល់លែងអាចប្រើកម្លាំងបាយមកលើទ្រង់ទៀតហើយ។ ទ្រង់បានលើកទៅស្ថានសួគ៌គង់នៅស្ដាំព្រះហស្ដរបស់ព្រះវរបិតាធ្វើជាស្ដេចហើយមានសុវត្ថិភាព សន្តិភាពនិងអំណរដ៏នៅអស់កល្បជានិច្ច។

> ចូរមើល មនុស្សបរិសុទ្ធ ទស្សនីភាពមានពេញដោយសិរីល្អ
> ចូរមើលមនុស្សដែលមានទុក្ខលំបាក
> បានមកផែនដីតយុទ្ធហើយត្រឡប់ទៅស្ថានសួគ៌ដោយជ័យជំនះ
> គ្រប់ទាំងជង្គង់លុតចុះថ្វាយបង្គំទ្រង់

រាជាភិសេកឲ្យទ្រង់ រាជាភិសេកឲ្យទ្រង់
រាជាភិសេកឲ្យទ្រង់ រាជាភិសេកឲ្យទ្រង់...
ចូរស្តាប់អស់អ្នកដែលស្រែកសាទរ!
ចូរស្តាប់តន្ត្រីជ័យជំនះដ៏លាន់រំពង!
ព្រះយេស៊ូវយាងទៅទីខ្ពស់បំផុត
ទស្សនី ភាពផ្តល់អំណរដ៏ធំក្រៃលែង!
រាជាភិសេកឲ្យទ្រង់! រាជាភិសេកឲ្យទ្រង់
ស្តេចលើអស់ទាំងស្តេច ហើយព្រះអម្ចាស់លើអស់ទាំងព្រះអម្ចាស់!
ស្តេចលើអស់ទាំងស្តេច ហើយព្រះអម្ចាស់លើអស់ទាំងព្រះអម្ចាស់![៤]

## *ព្រះគ្រីស្ទគង់នៅខាងស្តាំព្រះវរបិតា*

“ក្នុងនាមទ្រង់ជាស្តេចដ៏ជាអ្នកសង្រ្គោះសង្រ្គោះមទ្រង់គង់នៅខាងស្តាំនៃព្រះដ៏ជាព្រះវរបិតាគ្រប់គ្រងទាំងនៅស្ថានសួគ៌និងផែនដីដោយនូវអស់ទាំងអធិបតេយ្យភាពរបស់ព្រះហើយទ្រង់ជាសម្តេចសង្ឃនិងជាអ្នកការពារក្តីដ៏សុចរិតរបស់យើងរាល់គ្នា។”។ ប៉ុន្មានឆ្នាំមុនខ្ញុំបានកំពុងដឹកនាំក្រុមគ្រូគង្វាល បេសកជន និងប្តីប្រពន្ធរបស់ពួកគេសម្រាប់សេចក្តីអធិស្ឋាន។ មុនពេលយើងបានអធិស្ឋាន ខ្ញុំសូមឲ្យពួកគេបិទភ្នែករបស់ពួកគេ ហើយនឹកក្នុងមនោគតិអំពីព្រះយេស៊ូវគ្រីស្ទ។ មួយភ្លែតក្រោយមក ខ្ញុំបានសូមឲ្យពួកគេចែកចាយនូវអ្វីដែលពួកគេបានឃើញនៅក្នុងមនោគតិរបស់ពួកគេ។ មនុស្សម្នាក់បានឃើញថា ព្រះយេស៊ូវកំពុងស្រលាញ់និងប្រទានពរដល់កូនក្មេង ម្នាក់ទៀតបានឃើញទ្រង់កំពុងបង្រៀន

ហ្វូងមនុស្ស ម្នាក់ទៀតបានឃើញថា ទ្រង់កំពុងធ្វើឲ្យនំបុ័ងនិងត្រីកើនចំនួន ម្នាក់ទៀតបានឃើញថា ទ្រង់កំពុងអធិស្ឋាននៅក្នុងសួនច្បារគែតសេម៉ានី។

តាមរយៈការពិចារណា យើងបានយល់ថា រូបភាពអំពីទ្រង់ទាំងអស់របស់យើងគឺនៅពេលមុនការលើកឡើងទៅស្ថានសួគ៌។ ការនឹកក្នុងមនោគតិអំពីព្រះយេស៊ូវរបស់យើងខុសពីស្ថានភាពរបស់ទ្រង់បច្ចុប្បន្ននេះ។ ការលើកតម្កើងរបស់ព្រះយេស៊ូវគ្រីស្ទមិនគ្រាន់តែជាព្រឹត្តិការណ៍ប្រវត្តិសាស្ត្រប៉ុណ្ណោះទេ ប៉ុន្តែក៏ជាសេចក្តីពិតបច្ចុប្បន្នផងដែរ។ ព្រះយេស៊ូវលែងមានសាច់ឈាមទៅទៀតហើយ ប៉ុន្តែនៅក្នុងសិរីល្អដែលមិនចេះពុករលួយវិញ។ នៅពេលសាវ័កយ៉ូហានឃើញព្រះយេស៊ូវនៅក្នុងនិមិត្ត នោះយ៉ូហានឃើញព្រះយេស៊ូវតាមស្ថានភាពរបស់ទ្រង់បច្ចុប្បន្ននេះហើយគាត់ដួលដូចជាស្លាប់ (វិវរណៈ ១:១៧)។

ព្រះគ្រីស្ទដែលបានលើកតម្កើងនិងមានសិរីរុងរឿងនិងអំណាចព្រះចេស្តានេះ គឺជាព្រះគ្រីស្ទដែលយ៉ូហានបានស្គាល់ ស្រឡាញ់ ថ្វាយបង្គំនិងបម្រើ។ ឥឡូវនេះព្រះគ្រីស្ទគ្រប់គ្រងជាស្តេចសម្រុះសម្រួល ទូលអង្វរជំនួសយើង គ្រប់គ្រងយើង និងការពារយើង។ ទ្រង់បានយករូបសាច់របស់យើងទៅក្នុងព្រះត្រៃឯកជាកន្លែងដែលទ្រង់ជាអ្នកតំណាងឥតខ្ចោះរបស់យើងហើយទ្រង់ការពារយើងជាដរាបទៅ។ ដូច្នេះ យើងគ្មានអ្វីគួរឲ្យភ័យខ្លាចនោះទេ គឺត្រូវកោតខ្លាចព្រះអង្គតែមួយប៉ុណ្ណោះ (ម៉ាថាយ ១០:២៨)។

## *ការយាងត្រឡប់មកវិញប្រកបដោយសិរីល្អរបស់ទ្រង់*

ព្រះគ្រីស្ទនឹងយាងត្រឡប់មកវិញនៅក្នុងសិរីល្អដើម្បីធ្វើឲ្យគ្រប់យ៉ាងបាន

ពេញលេញ ហើយទទួលតំណែងជាស្ដេចពេញសិទ្ធិនិងព្រះអម្ចាស់ដែលបានលើកតម្កើង ដែលលោកិយទាំងមូលរួបរួមនៅក្នុងការសរសើរតម្កើងមិនចេះចប់ (អេភេសូរ ១:១០)។

## ព្រះគ្រីស្ទជាអ្នកតំណាងនិងអ្នកជំនួសរបស់យើង

“យើងជឿថាដោយសារការយកកំណើតជាមនុស្សព្រះជន្មរស់នៅការសុគតការរស់ឡើវិញនិងការយាងឡើងទៅស្ថានសួគ៌វិញរបស់ទ្រង់នោះព្រះយេស៊ូវគ្រីស្ទទ្រង់បានធ្វើជាអ្នកតំណាងនិងជំនួសឲ្យយើងរាល់គ្នា។ទ្រង់ធ្វើដូច្នោះគឺដើម្បីឲ្យយើងដែលនៅក្នុងទ្រង់អាចក្លាយជាសេចក្ដីសុចរិតរបស់ព្រះ»។ យើងមានហេតុផលគ្រប់គ្រាន់ដើម្បីសរសើរតម្កើងនិងស្រលាញ់ព្រះយេស៊ូវគ្រីស្ទ ថ្វីបើយើងគ្រាន់តែដឹងចំនុចផ្សេងៗដែលត្រូវបានពិភាក្សានៅក្នុងជំពូកនេះរួចទៅហើយប៉ុណ្ណោះ (ដូចជាភាពជាព្រះអស់កល្បជានិច្ចរបស់ទ្រង់ ការស្ដាប់បង្គាប់ដោយសេចក្ដីស្រលាញ់របស់ទ្រង់ចំពោះព្រះវរបិតារបស់ទ្រង់ ការបន្ទាបខ្លួនរបស់ទ្រង់ ហើយនិងសិរីល្អខ្ពស់បំផុតរបស់ទ្រង់នៅ ខាងស្ដាំព្រះហស្ដរបស់ព្រះ)។ ទោះយ៉ាងណា ព្រះគម្ពីរផ្ដល់ឲ្យយើងនូវហេតុផលទៀតដើម្បីស្រឡាញ់និងបម្រើទ្រង់។ គ្រប់យ៉ាងដែលទ្រង់បានធ្វើ គឺទ្រង់បានធ្វើសម្រាប់យើង។

ទ្រង់បានកើតមកក្នុងលោកិយនេះសម្រាប់យើង (កាឡាទី ៤:៤-៧) ទ្រង់ត្រូវជាប់ឆ្កាងជំនួសអំពើបាបរបស់យើង (កាឡាទី ៣:១៣) ទ្រង់ត្រូវបានប្រោសឲ្យរស់ឡើងវិញដើម្បីព្រះអង្គនឹងរាប់យើងជាសុចរិត (រ៉ូម ៤:២៥) ទ្រង់បានលើកឡើងទៅស្ថានសួគ៌ដើម្បីរៀបចំកន្លែងសម្រាប់យើង (យ៉ូហាន

១៤:១២)។ បទគម្ពីរប្រាប់យើងថា ព្រះគ្រីស្ទបានធ្វើការនេះដោយព្រះអង្គក្លាយជាអង្គជំនួស ដើម្បីទ្រង់អាចធ្វើជំនួសយើងនូវអ្វីដែលយើងមិនអាចធ្វើសម្រាប់ខ្លួនឯងបាន។ សេចក្តីពិតនេះស្ថិតចំកណ្តាលសេចក្តីជំនឿរបស់គ្រីស្ទបរិស័ទ ហើយបើសិនជាគ្មានសេចក្តីពិតនេះ នោះដំណឹងល្អបាត់បង់អំណាចពិសេសរបស់ខ្លួនហើយ។

សាសនាជាច្រើនបង្រៀនយើងថា យើងត្រូវការកែទម្រង់ ហើយសាសនាខ្លះផ្តល់ឲ្យយើងនូវគំរូដ៏អស្ចារ្យដែលយើងគួរតែដណ្តើមតាមដូចជា អ័ប្រាហាំ និងម៉ូសេ (សាសនាយូដា) ព្រះយេស៊ូវ (ជំនឿគ្រីស្ទបរិស័ទ) មហាម៉ាត់ (សាសនាអ៊ីស្លាម) ព្រះពុទ្ធ និងដាឡៃឡាម៉ា Dalai Lama (ពុទ្ធសាសនា) ខុងជឺ (សាសនាខុងជឺ)...ល។ ប៉ុន្តែមានតែសាសនាមួយ (ជំនឿគ្រីស្ទបរិស័ទដែលជឿលើដំណឹងល្អ) បង្រៀនយើងថា មានម្នាក់ផ្សេងទៀតបានជំនួសយើងដោយ ១. បានរស់ជីវិតបរិសុទ្ធនោះរួចហើយ ២. ទទួលយកទណ្ឌកម្មដែលយើងសមនឹងទទួលសម្រាប់អំពើបាបរបស់យើង ហើយ ៣. បានទទួលជីវិតដែលរស់ពីសុគតឡើងវិញ និងឋានៈដែលលើកតម្កើង ដើម្បីឲ្យយើង (និយាយខាងព្រលឹងវិញ្ញាណ) បានអង្គុយនៅខាងស្តាំព្រះហស្តរបស់ព្រះរួចទៅហើយ។ នេះគឺជាសេចក្តីអាថ៌កំបាំងនៃសេចក្តីជំនឿរបស់គ្រីស្ទបរិស័ទ (កូល៉ុស ១:២៥, ១ធីម៉ូថេ ៣:១៦)៖ តាមរយៈជីវិតជាអង្គជំនួសនិងការសុគតរបស់ព្រះអម្ចាស់ព្រះយេស៊ូវគ្រីស្ទរបស់យើង យើងត្រឡប់ជាសេចក្តីសុចរិតរបស់ព្រះ (២កូរិនថូស ៥:២១)។

## *ជីវិតដែលគ្មានបាបជំនួសយើង*

ព្រះគម្ពីរបង្រៀនថា អ័ដាមដែលជាមនុស្សដំបូង ពិតជាអ្នកតំណាងដំបូងរបស់យើង (រ៉ូម ៥:១២)។ ក្នុងនាមជាអ្នកតំណាងរបស់យើង បើសិនគាត់បានជ័យជំនះ នោះយើងក៏បានជ័យជំនះ ប៉ុន្តែបើសិនគាត់បានបរាជ័យ នោះយើងក៏បរាជ័យផងដែរ។ គាត់បានបរាជ័យ។ យើងបានបរាជ័យ។ គាត់បានធ្វើបាប ដូច្នេះយើងធ្វើបាប។ គាត់បានត្រឡប់ជាមនុស្សមានបាប ដូច្នេះយើងគឺជាពួកមនុស្សមានបាប។ តើការនេះអយុត្តិធម៌ទេ? តើអ្នកគិតថាអ្នកអាចធ្វើបានប្រសើរជាងអ័ដាមដែរទេ? បើអ្នកគិតដូច្នេះ នោះជាអំនួតរបស់អ្នក បញ្ជាក់ថាអ្នកជាមនុស្សមានបាបម្តងទៀតហើយ។

ទោះយ៉ាងណា សាច់រឿងគឺថា បន្ទាប់ពីការធ្លាក់ចុះរបស់មនុស្ស ព្រះបានសន្យាភ្លាមៗថានឹងប្រទានអ្នកតំណាងថ្មីមួយ ជាពូជរបស់អេវ៉ាដែលនឹងកិនខ្មាំងសត្រូវ (សាតាំង) របស់យើង (លោកុប្បត្តិ ៣:១៥)។ ព្រះយេស៊ូវគឺជាពូជនោះ ជាអ័ដាមទីពីរ ហើយទ្រង់បានរស់នៅយ៉ាងឥតខ្ចោះជំនួសយើងដើម្បីនៅពេលយើងជឿទុកចិត្តលើទ្រង់ នោះយើងទទួលបានផលប្រយោជន៍ដែលមកអំពីការស្តាប់បង្គាប់ឥតខ្ចោះរបស់ទ្រង់ចំពោះព្រះវរបិតា។ គ្រប់យ៉ាងដែលទ្រង់បានធ្វើចូលក្នុងកំណត់ត្រារបស់យើង។ នៅពេលព្រះមើល “កំណត់ត្រាការប្រព្រឹត្ត” របស់ពួកគ្រីស្ទបរិស័ទ នោះទ្រង់មើលឃើញកំណត់ត្រាដែលព្រះរាជបុត្រាស្ងួនភ្ងារបស់ទ្រង់គឺព្រះយេស៊ូវបានសម្រេចបាន។ ព្រះបានរាប់ទុកយើងមានជីវិតសុចរិតដ៏ឥតខ្ចោះដែលព្រះរាជបុត្រាបានរស់។ វាជាការពិតដែលព្រះយេស៊ូវបានរស់នៅក្នុងជីវិតដែលគ្មានបាបជំនួសយើង។

## *ការសុគតដ៏ឈឺចាប់មួយជំនួសយើង*

ជារឿយៗយើងប៉ាន់ប្រមាណលើទំហំនៃអំពើបាបរបស់យើង (និងលទ្ធផលមកពីអំពើបាបរបស់យើង) ខុសយ៉ាងខ្លាំង។ ជាលទ្ធផលនៃការធ្លាក់ចុះរបស់អ័ដាម នោះយើងគឺជាពួកមនុស្សមានបាបហើយមានទោសដែលត្រូវទទួលសេចក្តីក្រោធរបស់ព្រះ យើងពុករលួយក្នុងគ្រប់ចំនុចនៃលក្ខណៈរបស់យើង យើងដាច់ចេញពីព្រះ បានត្រឡប់ជាខ្មាំងសត្រូវរបស់ទ្រង់ ហើយយើងគ្មានសេចក្តីសង្ឃឹមខាងសីលធម៌និងព្រលឹងវិញ្ញាណដើម្បីផ្លាស់ប្តូរ ឬសង្គ្រោះខ្លួនឯងនោះទេ។ មានតែការសុគតជំនួសរបស់ព្រះអម្ចាស់ព្រះយេស៊ូវប៉ុណ្ណោះដែលអាចដោះស្រាយបញ្ហាដ៏ធ្ងន់ធ្ងរទាំងនេះបាន។

ព្រះយេស៊ូវបានសុគតជំនួសយើង។ ទ្រង់មិនសមនឹងសុគតនោះទេ។ យើងទេសមនឹងស្លាប់។ ទ្រង់បានសុគតដោយព្រោះព្រះបានដាក់អំពើបាបរបស់យើងទៅលើព្រះរាជបុត្រាស្ងួនភ្ងាររបស់ទ្រង់ផ្ទាល់សម្រាប់សិរីល្អរបស់ទ្រង់និងពីព្រះគុណគ្មានកំណត់របស់ទ្រង់ចំពោះយើង។ ហើយតាមរយៈការសុគតជាយញ្ញបូជារបស់ទ្រង់ នោះព្រះយេស៊ូវគ្រីស្ទបានផ្ទុកអំពើបាបរបស់យើងនៅក្នុងរូបកាយទ្រង់ ហើយយកវាចេញឆ្ងាយពីយើង។ យ៉ូហានបាទីស្ទនិយាយចង្អុលបង្ហាញទៅកាន់ព្រះយេស៊ូវថា “នុះន៏ កូនចៀមនៃព្រះដែលដោះបាបមនុស្សលោក” (យ៉ូហាន ១:២៩, ៣៦)។ ព្រះយេស៊ូវគ្រីស្ទបានដោះបាបរបស់យើងដោយការយកបាបរបស់យើងដាក់លើអង្គទ្រង់។ “ព្រះទ្រង់បានធ្វើឲ្យត្រឡប់ជាតួបាប ជំនួសយើងរាល់គ្នាវិញ ដើម្បីឲ្យយើងរាល់គ្នាបានត្រឡប់ទៅជាសេចក្តីសុចរិតរបស់ព្រះដោយនូវព្រះអង្គនោះឯង”

(២កូរិនថូស ៥:២១)។

ប៉ុលពន្យល់អំពីមូលហេតុដែលព្រះយេស៊ូវពិតជាបានសុគតនៅលើឈើឆ្កាង “ព្រះគ្រីស្ទទ្រង់បានលោះយើងរាល់គ្នា ឲ្យរួចពីសេចក្តីបណ្តាសារបស់ក្រឹត្យវិន័យ ដោយទ្រង់ត្រូវបណ្តាសាជំនួសយើងរាល់គ្នា (ដ្បិតមានសេចក្តីចែងទុកមកថា “បណ្តាសាហើយអ្នកណាដែលត្រូវព្យួរនៅលើឈើ”“ (កាឡាទី ៣:១៣)។ តាមរយៈការត្រូវបណ្តាសាជំនួសយើង ព្រះយេស៊ូវគ្រីស្ទបានធ្វើឲ្យស្ងប់សេចក្តីក្រោធដ៏សុចរិតរបស់ព្រះចំពោះអស់អ្នកដែលធ្វើបាប គឺព្រះគ្រីស្ទ បានថ្វាយដង្វាយឲ្យយើងរួចពីសេចក្តីក្រោធរបស់ព្រះ។ ទ្រង់បង្វែរសេចក្តីក្រោធរបស់ព្រះចេញពីយើង។ ទ្រង់បានបំពេញសេចក្តីតម្រូវនៃយុត្តិធម៌របស់ព្រះ។ យញ្ញបូជាជំនួសនេះចាំបាច់សម្រាប់សេចក្តីសង្គ្រោះរបស់យើងពីព្រោះ “ឯអ្នកណាដែលជឿដល់ព្រះរាជបុត្រា នោះមានជីវិតដ៏នៅអស់កល្បជានិច្ចហើយ តែអ្នកណាដែលមិនព្រមជឿដល់ព្រះរាជបុត្រាវិញ នោះនឹងមិនឃើញជីវិតសោះឡើយ គឺសេចក្តីក្រោធរបស់ព្រះតែនៅជាប់លើអ្នកនោះឯង” (យ៉ូហាន ៣:៣៦)។

ប៉ុលពិពណ៌នាយើងនៅក្នុងលក្ខខណ្ឌធ្លាក់ចុះថា “ស្លាប់ក្នុងការរំលងហើយក្នុងអំពើបាប (របស់យើង)....ហើយជាប់ក្នុងសេចក្តីខ្ញាល់” (អេភេសូរ ២:១, ៣)។ តែព្រះគ្រីស្ទបានសុគតជំនួសយើងក្នុងកាលដែលយើងជាខ្មាំងសត្រូវរបស់ព្រះ និងនៅមានបាបនៅឡើយ (រ៉ូម ៥:៨)។ ទីបំផុត ឈាមរបស់ព្រះគ្រីស្ទ យញ្ញបូជាសុគតរបស់ទ្រង់សម្រាប់យើង ផ្សះផ្សាយើងនឹងព្រះ ដើម្បីឲ្យយើងទទួលបានភាពស្និទ្ធស្នាលជាមួយទ្រង់ដែលយើងបានបាត់

បង់នៅក្នុងសួនច្បារអេដែនដោយសារអំពើបាបរបស់យើង។ ប៉ុលនិយាយដូចនេះថា “គ្រប់ទាំងអស់ក៏មកពីព្រះ ដែលទ្រង់បានផ្សះផ្សាយើងនឹងព្រះអង្គទ្រង់ ដោយសារព្រះយេស៊ូវគ្រីស្ទ ហើយបានប្រទានការងារផ្សះផ្សានោះមកយើងខ្ញុំដែរ គឺពីដំណើរដែលព្រះទ្រង់គង់ក្នុងព្រះគ្រីស្ទ កំពុងផ្សះផ្សាលោកិយនឹងអង្គទ្រង់ ឥតប្រកាន់ទោសគេទៀត ហើយទ្រង់បានប្រគល់ព្រះបន្ទូលពីការផ្សះផ្សានោះមកយើងខ្ញុំ” (២កូរិនថូស ៥:១៨-១៩)។ ការសុគតដ៏ឈឺចាប់របស់ទ្រង់គឺដើម្បីជំនួសយើង។

## *ការរស់ពីសុគតឡើងវិញដ៏មានជ័យជំនះសម្រាប់យើង*

ដោយសារអំពើបាប នោះយើងបានត្រឡប់ជានៅក្រោមអំណាចទុក្ខវេទនារបស់ជីវិតនេះ សេចក្ដីស្លាប់ និងស្ថាននរកដ៏នៅអស់កល្ប។ ដោយសារការងារជំនួសនិងប្រោសលោះរបស់ទ្រង់ នោះព្រះយេស៊ូវបានមានជ័យជំនះលើអំពើបាប សេចក្ដីស្លាប់ និងអំណាចទាំងអស់ដែលចង់បំផ្លាញយើង។ ដោយសារការរស់ពីផ្នូរឡើងវិញរបស់ទ្រង់ នោះជាចុងបំផុតនិងជាដរាបទៅយើងបានរាប់ជាសុចរិតនៅចំពោះព្រះ ហើយបានរស់ឡើងវិញមកកាន់ជីវិតថ្មីដ៏នៅអស់កល្បជានិច្ច។ តាមរយៈសេចក្ដីជំនឿក្នុងព្រះយេស៊ូវគ្រីស្ទ នោះខាងវិញ្ញាណយើងបានប្រោសឲ្យរស់ជាមួយទ្រង់រួចរាល់ទៅហើយ ហើយថ្ងៃមួយយើងនឹងត្រឡប់ដូចជាទ្រង់នៅក្នុងរូបកាយថ្មីដែលរស់ពីស្លាប់ឡើងវិញដែរ។ អនាគតរបស់យើងជាប់ទាក់ទងយ៉ាងជិតស្និទជាមួយទ្រង់ ដោយការបន្ទាបខ្លួនរបស់យើងត្រឡប់ជាកាបន្ទាបខ្លួនរបស់ទ្រង់ នោះការតម្កើងឡើងរបស់ទ្រង់បាន

ត្រឡប់ជាការតម្កើងឡើងរបស់យើងផងដែរ។ យើងបានរស់ឡើងវិញ យើងបានលើកឡើងទៅឯព្រះវត្តមានព្រះ យើងគ្រប់គ្រងជាមួយព្រះគ្រីស្ទ ថ្ងៃមួយយើងនឹងដូចជាទ្រង់នៅក្នុងរូបកាយឧត្តម។ ការរស់ពីសុគតឡើងវិញដែលមានជ័យជំនះរបស់ទ្រង់គឺសម្រាប់យើង។

## *ការលើកឡើងទៅស្ថានសួគ៌ដ៏មានសិរីល្អសម្រាប់យើង*

នៅពេលព្រះយេស៊ូវគង់ជាមួយពួកសិស្សរបស់ទ្រង់នៅបន្ទប់ខាងលើ (យ៉ូហាន ១៣-១៧) ទ្រង់បានជ្រាបថា ពួកគេថប់បារម្ភពីព្រោះទ្រង់នឹងចាកចេញពីពួកគេនាពេលអនាគត។ ទ្រង់បានពន្យល់ពួកគេថា មានពីរយ៉ាងការចាកចេញរបស់ទ្រង់នឹងនាំមកនូវការល្អ។ ទីមួយ ទ្រង់នឹងបញ្ជូនព្រះវិញ្ញាណបរិសុទ្ធមកកាន់ពួកគេ។ ព្រះវិញ្ញាណបរិសុទ្ធគឺជាព្រះដ៏ជាជំនួយ ដែលនឹងដឹកនាំ លើកទឹកចិត្ត និងបង្រៀនពួកគេ។ ទីពីរ ទ្រង់នឹងយាងទៅដំណាក់របស់ព្រះវរបិតាទ្រង់ដើម្បីរៀបចំកន្លែងមួយសម្រាប់ពួកគេ។

នៅពេលខ្ញុំនៅក្មេង ពេលសំខាន់មួយក្នុងជីវិតរបស់ខ្ញុំគឺពេលខ្ញុំទៅសួរសុខទុក្ខយាយដែលជាម្ដាយរបស់ម្ដាយរបស់ខ្ញុំមួយឆ្នាំម្ដង ហើយយើងបានស្នាក់នៅក្នុងផ្ទះតូចរបស់គាត់រយៈពេលច្រើនថ្ងៃ។ គាត់បានរស់នៅក្នុងភូមិតូចនៅជនបទក្បែរតំបន់ភ្នំ។ ប្រហែលជាអ្នកឆ្ងល់ថាហេតុអ្វីបានជាក្មេងអាយុប្រាំបីឆ្នាំរីករាយនឹងការទៅលេងកន្លែងមួយដែលគ្មានទូរទស្សន៍ គ្មានតារាងបាល់ទះ គ្មានប្រដាប់ក្មេងលេងទំនើបៗ ហើយមានតូចលក់ឥវ៉ាន់តូចមួយនៅឯផ្លូវអញ្ចឹង។ ដោយព្រោះតែយាយបានកំពុងរង់ចាំពួកយើងអស់

ជាច្រើនខែ។ ពេលយើងមកដល់ គាត់កំពុងរង់ចាំយើងនៅផ្ទះត្រង់ឯទ្វារ។ យើងបានរត់ទៅដើម្បីឲ្យគាត់អោបយើងដោយក្ដីស្រឡាញ់។ គាត់បានដាក់សម្មតិនាមឲ្យយើង។ យើងបានឡើងបន្ទប់គេងរបស់យើងនៅជាន់ខាងលើដែលមានដំបូលស័ង្កសីដែលមានសំឡេងថ្លង់ខ្លាំងពេលភ្លៀងនៅពេលយប់ ហើយបន្ទាប់មកគាត់បានរៀបចំអាហារនិងបង្អែមឆ្ងាញ់ពិសារសម្រាប់ពួកយើង។ យើងបានដើរលេងកាត់ភ្នំ ហើយធ្វើសកម្មភាពធម្មតាដែលយាយគាត់គ្រោងទុកសម្រាប់យើង។ ដំបូងបង្អស់ យើងរីករាយដោយព្រោះសេចក្ដីស្រឡាញ់របស់យាយចំពោះយើង។

បើសិនយាយរបស់ខ្ញុំដែលមានអាយុចិតសិបប្រាំឆ្នាំមានទ្រព្យសម្បត្តិតិចតួច អាចត្រៀមរៀបចំកន្លែងដែលគួរឲ្យសប្បាយរីករាយសម្រាប់ខ្ញុំបាន តើអ្នកអាចនឹកក្នុងមនោគតិអំពីអ្វីដែលព្រះអម្ចាស់ព្រះយេស៊ូវគ្រីស្ទដែលមានទ្រព្យសម្បត្តិច្រើនមហិមា មានអំណាចគ្មានកំណត់ និងមានសេចក្ដីស្រលាញ់គ្មានព្រំដែន នឹងធ្វើសម្រាប់យើងបានទេ? ទ្រង់ទន្ទឹងរង់ចាំការមកដល់របស់យើង ទ្រង់មានសម្មតិនាមសម្រាប់រាស្ត្រម្នាក់ៗរបស់ទ្រង់ ទ្រង់បានត្រៀមរៀបចំកន្លែងដើម្បីឲ្យយើងមានអំណរជាដរាបទៅ។ យើងនឹងហែលក្នុងមហាសមុទ្រនៃសេចក្ដីស្រឡាញ់របស់ទ្រង់សម្រាប់យើង។ ការលើកឡើងទៅស្ថានសួគ៌របស់ទ្រង់គឺសម្រាប់យើង។

## ព្រះគ្រីស្ទជាសេចក្ដីសង្ឃឹមតែមួយគត់របស់យើង

“យើងជឿថាគ្មានសេចក្ដីសង្គ្រោះដោយសារអ្នកណាទៀតសោះដ្បិតនៅក្រោម

មេឃគ្មាននាមឈ្មោះណាទៀតបានប្រទានមកមនុស្សលោកឲ្យយើងរាល់គ្នាបានសង្គ្រោះនោះឡើយ»។ អស់ជាច្រើនសតវត្សពួកអ្នកមិនជឿបានប្រមាថមើលងាយចំនុចខ្លះៗនៃសេចក្ដីជំនឿរបស់គ្រីស្ទបរិស័ទ។ ចំនុចទាំងនេះរួមទាំងសេចក្ដីពុករលួយនៃចិត្តរបស់មនុស្ស ភាពឥតប្រយោជន៍របស់មនុស្សក្នុងព្យាយាមសង្គ្រោះខ្លួនឯងចេញពីលក្ខខណ្ឌបាត់បង់របស់ខ្លួន ហើយនិងសេចក្ដីពិតអំពីស្ថាននរក។ នៅក្នុងសម័យសាវ័កប៉ុលក៏មានសេចក្ដីបង្រៀនរបស់គ្រីស្ទបរិស័ទដែលពួកអ្នកមិនជឿបានប្រមាថមើលងាយផងដែរដូចជាការជំនុំជំរះរបស់ព្រះ លើអ៊ីស្រាអែល ពួកជំនុំរាប់បញ្ចូលពួកសាសន៍ដទៃនិងសេរីភាពរបស់គ្រីស្ទបរិស័ទពីច្បាប់ពិធីសាសនាក្នុងព្រះគម្ពីរសញ្ញាចាស់។

សេចក្ដីពិតដែលប្រមាថមើលងាយខ្លាំងបំផុតនៅក្នុងសម័យនេះប្រហែលជាសេចក្ដីបង្រៀនរបស់ព្រះគម្ពីរដែលថាព្រះយេស៊ូវគ្រីស្ទជាផ្លូវតែមួយគត់ទៅកាន់ជីវិតអស់កល្ប។ ហេតុផលសម្រាប់ការប្រមាថមើលងាយគឺច្បាស់ថាពួកគ្រីស្ទបរិស័ទកំពុងប្រកាសថា មានតែពួកគេទេដែលស្គាល់និងប្រកាសអំពីព្រះពិតតែមួយដ៏មានព្រះជន្មរស់ ហើយអ្នកផ្សេងទៀតគឺខុស ហើយថាលទ្ធផលនៃការខុសរបស់ពួកគេគឺមានភាពឃោរឃៅយ៉ាងខ្លាំង (ធ្លាក់ចូលបឹងភ្លើង)។

លើសពីនេះ គ្រីស្ទបរិស័ទខ្លះហាក់ដូចជាមិនព្រួយបារម្ភអំពីការវិនិច្ឆ័យដែលអ្នកមិនជឿនិងក្រុមសាសនាដទៃទៀតនឹងទទួល។ ដូច្នេះ តើហេតុអ្វីយើងដែលនៅក្នុងក្រុមចម្រុះដំណឹងល្អនឹងធ្វើឲ្យសេចក្ដីពិតនេះជាការប្ដេជ្ញារបស់យើងខាងសេចក្ដីពិតដែលមិនអាចបដិសេធបោះចោលបាន? យើងធ្វើដូចនេះដោយព្រោះ៖

១. បើសិនមនុស្សម្នាក់មិនទទួលយកសេចក្តីពិតនេះអស់ពីចិត្តនោះទេ នោះគាត់មិនយល់ដំណឹងល្អរបស់ព្រះគ្រីស្ទទាល់តែសោះ។ បើសិនយើងជឿលើអ្វីដែលព្រះគម្ពីរបង្រៀនអំពីលក្ខណៈអាក្រក់របស់មនុស្សជាតិដែលធ្លាក់ចុះ (សេចក្តីពុករលួយខាងសីលធម៌របស់យើង សេចក្តីស្លាប់ខាងវិញ្ញាណរបស់យើង ការជំនុំជំរះសុចរិតរបស់ព្រះនាំឲ្យយើងធ្លាក់ស្ថាននរកអស់កល្បជានិច្ច) នោះយើងនឹងយល់និងជឿយ៉ាងច្បាស់លាស់លើដំណោះស្រាយដែលព្រះប្រទានឲ្យ ដែលជាផ្លូវតែមួយដែលអាចប្រោសលោះយើងចេញពីលក្ខខណ្ឌអាក្រក់របស់យើង។ ដោយសារយើងមិនមានសេចក្តីសុចរិតរបស់ខ្លួនឯង នោះយើងត្រូវតែទុកចិត្តលើសេចក្តីសុចរិតរបស់ព្រះគ្រីស្ទតែមួយគត់។ ដោយសារយើងបានស្លាប់នៅក្នុងការរំលងនិងអំពើបាបរបស់យើង នោះយើងត្រូវតែទទួលយកការអស្ចារ្យនៃជីវិតរស់ពីសុគតឡើងវិញពីព្រះគ្រីស្ទ។ ដោយសារយុត្តិធម៌របស់ព្រះដែលប្រឆាំងនឹងអំពើបាបរបស់យើងត្រូវតែផ្គាប់ព្រះហឫទ័យព្រះ (គឺ ព្រះអង្គត្រូវដាក់ទណ្ឌកម្មលើអំពើបាបរបស់យើង) នោះយើងត្រូវតែទទួលបានការធួននឹងបាបដែលជំនួសនិងឥតខ្ចោះរបស់ព្រះគ្រីស្ទ។ ដោយសារយើងមិនអាចមកឯព្រះដោយពឹងផ្អែកលើអំពើល្អរបស់យើងបាន យើងត្រូវតែពឹងផ្អែកលើការការពាររបស់ព្រះគ្រីស្ទសម្រាប់យើងនៅមុខបល្ល័ង្ករបស់ព្រះ។ ទាំងនេះគឺជាការសម្រេចបានពិសេសរបស់ការងារប្រោស

លោះរបស់ព្រះគ្រីស្ទដែលដោះស្រាយបញ្ហាអំពើបាបរបស់យើង។ ព្រះយេស៊ូវបានមានបន្ទូលថា «ខ្ញុំជាផ្លូវ ជាសេចក្ដីពិត ហើយជាជីវិត បើមិនមកតាមខ្ញុំ នោះគ្មានអ្នកណាទៅឯព្រះវរបិតាបានឡើយ» (យ៉ូហាន ១៤:៦)។

២. បើសិនមានផ្លូវផ្សេងទៀតយើងអាចទទួលបានជីវិតអស់កល្ប នោះព្រះនឹងមានទោសសម្រាប់ហិង្សាយុត្តិធម៌ដ៏ធំបំផុតនៅក្នុងប្រវត្តិសាស្ត្ររបស់សកលលោក។ តាមរបៀបមួយការជាប់ឆ្កាងរបស់ព្រះគ្រីស្ទគឺជាការអយុត្តធម៌ដ៏ខ្លាំងបំផុតនៅក្នុងប្រវត្តិសាស្ត្រ។ ដូចជាយើងបានមើលឃើញ ព្រះយេស៊ូវគឺមនុស្សតែមួយដែលមិនដែលបញ្ចេញពាក្យសំដីមានបាប មិនដែលមានគំនិតអាក្រក់ ឬមិនដែលធ្វើបាបនោះឡើយ។ ទ្រង់បានបម្រើអ្នកក្រីក្រដោយសេចក្ដីស្រឡាញ់ ទ្រង់មានសេចក្ដីមេត្តាករុណាចំពោះអ្នកទន់ខ្សោយនិងអ្នកកម្សត់ ហើយទ្រង់បានព្យាបាលអ្នកជម្ងឺ។ ទ្រង់គឺជាមនុស្សជាតិដ៏អស្ចារ្យបំផុតដែលបានរស់នៅ ប៉ុន្តែទ្រង់បានរងទុក្ខទណ្ឌកម្មឧក្រិដ្ឋកម្មដ៏ធ្ងន់ធ្ងរជាងគេនៅក្នុងប្រវត្តិសាស្ត្រទៅវិញ។ កាន់តែអស្ចារ្យទៅទៀត ព្រះបានកំណត់ការនេះឲ្យកើតឡើង គឺទ្រង់បានប្រគល់ព្រះរាជបុត្រារបស់ទ្រង់ទៅមនុស្សអាក្រក់ដើម្បីទទួលទុក្ខទណ្ឌកម្មនៃសេចក្ដីស្លាប់នៅលើឈើឆ្កាង (កិច្ចការ ២:២៣)។ បើសិនមានផ្លូវផ្សេងទៀតដើម្បីឲ្យមនុស្សបានសង្គ្រោះចេញពីស្ថាន

ភាពបាបរបស់ពួកគេ ហើយបើសិនព្រះមានផែនការណ៍ទីពីរដែលបានប្រសិទ្ធិភាព នោះយើងត្រូវតែសន្និដ្ឋានថា ការសុគតរបស់ព្រះយេស៊ូវគ្រីស្ទពិតជាមិនចាំបាច់សម្រាប់សេចក្តីសង្គ្រោះរបស់ពួកមនុស្សមានបាបឡើយ។ យើងត្រូវតែសន្និដ្ឋានបន្ថែមទៀតថាព្រះបានធ្វើអំពើអយុត្តធម៌ជាឥតប្រយោជន៍និងអាក្រក់បំផុត។ ប៉ុន្តែព្រះយេស៊ូវគឺជាផ្លូវតែមួយគត់ ដូច្នេះហើយព្រះរាជក្រឹត្យដ៏មុឹងម៉ាត់របស់ព្រះក្នុងការយកព្រះរាជបុត្រាតែមួយរបស់ទ្រង់ជាយញ្ញបូជាមិនមែនជាសកម្មភាពអយុត្តិធម៌ដ៏ធំបំផុតនោះទេ ប៉ុន្តែជាសកម្មភាពនៃសេចក្តីស្រលាញ់ដ៏ធំធេងបំផុតដែលបានសម្រេចបានវិញ។

៣. បើសិនមានផ្លូវផ្សេងទៀតដើម្បីបានសង្គ្រោះ នោះវាត្រូវតែពឹងផ្អែកលើការប្រព្រឹត្តខាងសីលធម៌របស់មនុស្ស ពីព្រោះដំណឹងល្អរបស់គ្រីស្ទបរិស័ទគឺជាផ្លូវតែមួយគត់ដែលមនុស្សអាចទទួលសេចក្តីសង្គ្រោះដោយសារព្រះគុណ ដូច្នេះសេចក្តីសង្គ្រោះតាមផ្លូវណាផ្សេងទៀតប្រឆាំងផ្ទាល់នឹងសេចក្តីសង្គ្រោះដោយសារព្រះគុណតែមួយគត់ហើយ ជាពិសេសនៅក្នុងសំបុត្រទាំងអស់របស់ប៉ុល។ បើសិនមានផ្លូវដទៃទៀតដើម្បីបានសង្គ្រោះ នោះព្រះគុណនឹងក្លាយទៅជាឥតប្រយោជន៍និងគ្មានប្រសិទ្ធិភាព ដូច្នេះហើយនឹងមិនមានដំណឹងល្អរបស់គ្រីស្ទបរិស័ទសោះឡើយ។

៤. បើសិនមានផ្លូវនៃសេចក្តីសង្គ្រោះផ្សេងទៀត នោះផ្ទុយនឹង

សេចក្តីថ្លែងច្បាស់លាស់របស់ព្រះគម្ពីរនោះទេ (យ៉ូហាន ១៤:៦ កិច្ចការ ៤:១២ រ៉ូម ៣:១៩-២០, ១ធីម៉ូថេ ២:៥-៦)។ បើសិនជាព្រះគម្ពីរមិនបង្រៀនយ៉ាងត្រឹមត្រូវអំពីគោលលទ្ធិដ៏សំខាន់បំផុត (ដំណឹងល្អ) នោះតើយើងអាចទុកចិត្តលើភាពត្រឹមត្រូវរបស់ព្រះគម្ពីរនៅក្នុងផ្នែកផ្សេងទៀតបានយ៉ាងដូចម្តេច?

៥. បើសិនមានផ្លូវនៃសេចក្តីសង្គ្រោះផ្សេងទៀត យើងអាចសន្តបានថា សេចក្តីសង្គ្រោះនោះត្រូវកំណត់ទុកសម្រាប់អស់អ្នកដែលមិនដែលស្តាប់ឮដំណឹងល្អ ហើយចង់ទៅស្ថានសួគ៌។ ប៉ុន្តែតើអ្វីធ្វើឲ្យមនុស្សគិតថា មនុស្សចង់ទៅស្ថានសួគ៌? ព្រះគម្ពីរបង្រៀនថា រាស្ត្រស្ថានសួគ៌គិតចង់សរសើរតម្កើងព្រះយេស៊ូវគ្រីស្ទដែលជាការមួយដែលអ្នកមិនជឿគេចមិនចង់ធ្វើ។ អស់អ្នកណាដែលមិនស្រលាញ់ព្រះគ្រីស្ទ នោះបានមើលងាយស្ថានសួគ៌ហើយ(ពីព្រោះនៅស្ថានសួគ៌យើងសរសើរព្រះគ្រីស្ទស្ថិតស្ថេរអស់កល្បជានិច្ច)។ ម៉្យាងវិញទៀត យើងពិតជាអាចនិយាយថា គ្មានអ្នកណាម្នាក់ដែលពិតជាប៉ងចង់ទៅស្ថានសួគ៌នឹងត្រូវកាត់ចោលទេ។ ព្រះប្រទានឲ្យទឹកចិត្តរបស់មនុស្សមានបាបនូវការប៉ងចង់ទៅស្ថានសួគ៌តាមរយៈតែការឮនិងជឿលើដំណឹងល្អ ដូច្នេះ ការស្តាប់បង្គាប់របស់ពួកជំនុំចំពោះបេសកកម្មដ៏អស្ចារ្យ (ម៉ាថាយ ២៨:១៧-២០) គឺមានសារៈសំខាន់ខ្លាំងណាស់។

អស់អ្នកដែលបានទទួលសេចក្ដីស្រឡាញ់របស់ព្រះតាមរយៈព្រះយេស៊ូវបានប្រោសលោះ គេមិនភ្ញាក់ផ្អើលចំពោះការដែលព្រះប្រទានផ្លូវតែមួយគត់ដើម្បីបានសង្គ្រោះនោះទេ តែគាត់កាន់ស្ងើចសរសើរ ពីព្រោះព្រះអង្គមិនចាំបាច់ត្រូវប្រទានសេចក្ដីសង្គ្រោះសោះ។ នៅពេលសិស្សគ្រីស្ទបរិស័ទរីកចម្រើនក្នុងការយល់អំពីខ្លួនឯង ដឹងអំពីភាពអាត្មានិយមខ្លាំងរបស់ខ្លួន អំនួតការប៉ងធ្វើព្រងើយកន្តើយចំពោះសេចក្ដីត្រូវការរបស់អ្នកដទៃ និងការបះបោរដែលមិនអាចដោះសារបានរបស់ខ្លួនចំពោះក្រឹត្យវិន័យដ៏បរិសុទ្ធរបស់ព្រះដ៏មានអំណាចព្រះចេស្ដានោះគាត់ស្ងើចសរសើរចំពោះសេចក្ដីសប្បុរស សេចក្ដីអត់ធ្មត់ សេចក្ដីមេត្តាករុណា និងសេចក្ដីស្មោះត្រង់របស់ព្រះវិញ។

តើហេតុអ្វីព្រះសង្គ្រោះមនុស្ស? សម្រាប់សិរីល្អរបស់ទ្រង់។ នេះគឺជាមូលហេតុដែលទ្រង់បើកសំដែងព្រះគុណរបស់ទ្រង់ចំពោះពួកមនុស្សមានបាបដែលមិនសមនឹងទទួលសេចក្ដីសង្គ្រោះ។ ពួកគ្រីស្ទបរិស័ទមិនដែលបាននិពន្ធបទចម្រៀងសរសើរតម្កើងដែលមានចំណងជើងថា “យុត្តិធម៌ដ៏អស្ចារ្យ” ឬ “សេចក្ដីក្រោធដ៏អស្ចារ្យ”។ សេចក្ដីក្រោធនិងយុត្តិធម៌របស់ទ្រង់មិនធ្វើឲ្យយើងភ្ញាក់ផ្អើលនោះទេ។ ព្រះបានព្រមានយើងអំពីសេចក្ដីក្រោធរបស់ទ្រង់នៅក្នុងសួនច្បារអេដែន។ ទេ ពួកគ្រីស្ទបរិស័ទបានតែងបទ “ព្រះគុណដ៏អស្ចារ្យ” (Amazing Grace) (យ៉ូហាន និវតុន John Newton)។

ក្នុងចំណោមពួកអ្នកដឹកនាំសាសនាទាំងអស់ដែលបានអះអាងជួយ ដឹកនាំ និងសង្គ្រោះមនុស្ស គឺមានតែព្រះយេស៊ូវគ្រីស្ទទេដែលពិតជាបានធ្វើការទាំងនេះ ហើយទ្រង់បានធ្វើការទាំងនេះដោយការលះបង់ព្រះលោហិតរបស់

ទ្រង់ផ្ទាល់។

## *ព្រះគ្រីស្ទជាគ្រប់ទាំងអស់សម្រាប់យើង*

សេចក្ដីថ្លែងអំពីសេចក្ដីជំនឿរបស់ក្រុមចម្រុះដំណឹងល្អនិយាយថា "ពីព្រោះទ្រង់បានរើសអ្នកទាបថោកនៅលោកិយនេះនិងពួកអ្នកដែលគេមើលងាយព្រមទាំងរបស់ដែលគ្មានផងដើម្បីនឹងលើកចោលរបស់ដែលមានចេញប្រយោជន៍កុំឲ្យមនុស្សណាបានអួតខ្លួននៅចំពោះព្រះឡើយគឺព្រះគ្រីស្ទទ្រង់បានត្រលប់ជាប្រាជ្ញាដែលមកពីព្រះហើយជាសេចក្ដីសុចរិតសេចក្ដីបរិសុទ្ធនិងសេចក្ដីប្រោសលោះដល់យើងផង" (សូមមើល១កូរិនថូស ១:២៨-៣០)។

ប្រហែលម្ភៃឆ្នាំមុន ភ្លាមៗបន្ទាប់ពីការថ្វាយបង្គំពេលព្រឹកថ្ងៃអាទិត្យ ខ្ញុំបានគិតថាខ្ញុំបានចែកចាយសេចក្ដីអធិប្បាយដ៏ល្អមួយ (មានគំនិតទេវសាស្រ្តល្អ ការកាត់ស្រាយបានត្រឹមត្រូវល្អ និងមានឧទាហរណ៍បញ្ជាក់ល្អ) ហើយខ្ញុំបានទទួលការសរសើរខ្លះៗពីសមាជិកពួកជំនុំដើម្បីអះអាងថាការវាយតម្លៃរបស់ខ្ញុំត្រឹមត្រូវ។ បន្ទាប់មកមានស្រ្តីចំណាស់ម្នាក់នៅបន្ទាប់ពីការថ្វាយបង្គំនិយាយជាមួយខ្ញុំ។ ខ្ញុំបានរំពឹងថាគាត់មានយោបល់ស្រដៀងគ្នានឹងសមាជិកពួកជំនុំដទៃទៀត ប៉ុន្តែខ្ញុំបានបន្ទាបខ្លួននៅពេលគាត់បាននិយាយថា "លោកគ្រូ អរគុណសម្រាប់សេចក្ដីអធិប្បាយដ៏ល្អរបស់លោកគ្រូ ប៉ុន្តែសប្ដាហ៍ក្រោយតើលោកគ្រូអាចប្រាប់ពួកយើងអំពីព្រះយេស៊ូវបានទេ?" ខ្ញុំបានដឹងខ្លួនថាពេលនោះខ្ញុំបានបរាជ័យក្នុងការធ្វើឲ្យព្រះយេស៊ូវជាគ្រប់ទាំងអស់នៅក្នុងការអធិប្បាយរបស់ខ្ញុំនិងក្នុងជីវិតរបស់ខ្ញុំ។

ដើម្បីយកព្រះគ្រីស្ទជាគ្រប់ទាំងអស់របស់យើង យើងត្រូវតែធ្វើការពីរយ៉ាង។ ទីមួយ យើងត្រូវតែធ្វើឲ្យខ្លួនយើងទទេ។ យើងប្រកាសអំពីទ្រង់ប្រាប់ដល់អ្នកដទៃនៅពេលយើងដឹងថាយើងពិតជាត្រូវការទ្រង់។ សាវ័កប៉ុលនិយាយថា មនុស្សខ្លះនឹងមិនបានគ្រងនគរព្រះឡើយ ពួកមនុស្សកំផិត ពួកថ្វាយបង្គំរូបព្រះ ពួកសហាយស្មន់ ពួកមនុស្សរួមភេទជាមួយភេទដូចគ្នាពួកចោរ ពួកមនុស្សលោភ ពួកប្រមឹក ពួកត្មះតិះដៀល និងពួកប្លន់កំហែង។ បន្ទាប់មកគាត់និយាយថា “ឯពួកអ្នករាល់គ្នាខ្លះ ពីដើមក៏ជាមនុស្សយ៉ាងដូច្នោះដែរ” (១កូរិនថូស ៦:៩-១១)។

ប៉ុលសរសេរពណ៌នាអំពីប្រវត្តិរបស់ពួកគ្រីស្ទបរិស័ទក្រុងកូរិនថូសថា “ក្នុងពួកអ្នកដែលទ្រង់បានហៅ មិនសូវមានអ្នកប្រាជ្ញច្រើនខាងសាច់ឈាម ឬច្រើនអ្នកមានអំណាច និងច្រើនអ្នកដែលមានត្រកូលខ្ពស់នោះទេ” (១កូរិនថូស ១:២៦-២៧)។ ព្រះមិនបានជ្រើសរើសយើងដោយសារយើងបានធ្វើអ្វី ឬនឹងធ្វើអ្វីដែលសមនឹងទទួលព្រះគុណរបស់ទ្រង់នោះឡើយ។ តែព្រះជ្រើសរើសយើងដោយសារតែព្រះគុណតែមួយប៉ុណ្ណោះ។ ប៉ុលពន្យល់អំពីលទ្ធផលនៃសេចក្តីពិតនេះនៅលើការវាយតម្លៃខ្លួនរបស់យើងថា “ដូច្នេះ សេចក្តីអួតអាងនៅឯណា? គឺត្រូវលើកចោលហើយ” (រ៉ូម ៣:២៧)។ បើសិនយើងបានសង្គ្រោះដោយសារដំណើងល្អ នោះទទួលស្គាល់ថា “ក្នុងសាច់ឈាមខ្ញុំ គ្មានអ្វីល្អទេ” (រ៉ូម ៧:១៨)។

ទីពីរ បើសិនយើងត្រូវតែឈប់អួតអំពីខ្លួនឯងនៅពេលយើងមកឯព្រះគ្រីស្ទនោះយើងក៏ត្រូវតែចាប់ផ្តើមអួតនៅក្នុងព្រះគ្រីស្ទវិញ។ “ឯខ្ញុំ កុំបីឲ្យខ្ញុំអួតខ្លួន

ឡើយ អួតបានតែពីឈើឆ្កាងនៃព្រះយេស៊ូវគ្រីស្ទ ជាព្រះអម្ចាស់នៃយើងរាល់គ្នាប៉ុណ្ណោះ ដែលដោយសារទ្រង់ នោះលោកិយបានត្រូវជាប់ឆ្កាងខាងឯខ្ញុំ ហើយខ្ញុំខាងឯលោកិយដែរ» (កាឡាទី ៦:១៤)។ ឥឡូវយើងអួតបានតែមួយ គឺអួតពីព្រះអង្គទ្រង់។ ស្តេចដាវីឌបានបន្លឺថា «ព្រលឹងរបស់ខ្ញុំនឹងអួតតែពីព្រះយេហូវ៉ា.....ចូរតម្កើងព្រះយេហូវ៉ាជាមួយនឹងខ្ញុំចុះ ចូរយើងព្រមគ្នាលើកព្រះនាមទ្រង់ឡើង» (ទំនុកដំកើង ៣៤:២-៣)។ តើហេតុអ្វីយើងអួតពីទ្រង់? ពីព្រោះទ្រង់តែមួយដែលបានសម្រេចបាននូវគ្រប់យ៉ាងដែលមានតម្លៃជាប់នៅសម្រាប់យើងដូចជា ព្រះទទួលយកយើងនៅចំពោះអង្គទ្រង់ សេចក្តីអំណរក្នុងជីវិតរបស់យើង ប្រាជ្ញាក្នុងការរស់នៅរបស់យើង និងសេចក្តីសង្ឃឹមសម្រាប់អនាគតរបស់យើង។ ទ្រង់គឺជាគ្រប់ទាំងអស់របស់យើង។ ដោយសារសេចក្តីប្រោសលោះដ៏មានសិរីល្អរបស់ទ្រង់សម្រាប់ពួកមនុស្សមានបាប ព្រះគ្រីស្ទបានត្រឡប់ជាចំនុចកណ្តាលនៃជីវិតរបស់យើង។

យើងអាចសិក្សាដំណឹងល្អដើម្បីមើលឃើញថា ការយកព្រះគ្រីស្ទជាចំនុចកណ្តាលនៃជីវិតរបស់យើងមានន័យយ៉ាងណា។ ជាឧទាហរណ៍នៅក្នុងដំណឹងល្អម៉ាថាយ យើងរៀនបានថា បើសិនយើងមានជីវិតដែលមានព្រះគ្រីស្ទជាចំនុចកណ្តាល នោះយើងថ្វាយបង្គំឫទ្ធានុភាពព្រះអម្ចាស់របស់ទ្រង់ (ម៉ាថាយ ២) យើងជឿព្រះរាជសាររបស់ទ្រង់ (ម៉ាថាយ ៤) យើងស្តាប់បង្គាប់សេចក្តីបង្រៀនរបស់ទ្រង់ (ម៉ាថាយ ៥-៧) យើងហៅព្រះថា «ព្រះវរបិតា» (ម៉ាថាយ ៦) យើងទទួលបានការព្យាបាលរបស់ទ្រង់ (ម៉ាថាយ ៨-៩) យើងពាក់ព័ន្ធនឹងបេសកកម្មរបស់ទ្រង់ (ម៉ាថាយ ១០) យើងលីឈើឆ្កាងរបស់យើង (ម៉ាថាយ

១៦) យើងស្រលាញ់ពួកជំនុំរបស់ទ្រង់ (ម៉ាថាយ ១៨) យើងស្រឡាញ់ព្រះគ្រីស្ទវិញ (ម៉ាថាយ ២៦) យើងអួតពីឈើឆ្កាងរបស់ទ្រង់ (ម៉ាថាយ ២៧ យើងអបអរសាទរការរស់ពីសុគតឡើងវិញរបស់ទ្រង់ (ម៉ាថាយ ២៨)។ នេះគឺជាជីវិតពិតដែលមានព្រះគ្រីស្ទជាចំនុចកណ្ដាល។

ដោយព្រោះភាពទទេរបស់យើងនិងភាពពេញលេញរបស់ទ្រង់ អំពើបាបរបស់យើងនិងសេចក្ដីសុចរិតរបស់ទ្រង់ សេចក្ដីចំកួតរបស់យើងនិងប្រាជ្ញារបស់ទ្រង់ នោះមានការជាប់ទាក់ទងទៅនឹងការងារប្រោសលោះព្រះយេស៊ូវគ្រីស្ទ

១. យើងត្រូវតែស្វែងរកសេចក្ដីស្កប់ចិត្តនៅក្នុងទ្រង់តែប៉ុណ្ណោះ។ ចូរយើងឈប់រអ៊ូរទាំនិងខិតខំស្វែងរកសេចក្ដីរីករាយរបស់លោកិយទៅ។ តើទ្រង់មិនគ្រប់គ្រាន់សម្រាប់យើងឬ? បើសិនអ្នកមានទ្រង់ តើអ្នកអាចស្កប់ចិត្តជាងនេះដែរទេ? ចូរមើលទៅឯសេចក្ដីស្កប់ចិត្តពេញលេញរបស់ប៉ុលទោះបីជាគាត់មានស្ថានភាពលំបាកផ្សេងៗ (សូមមើល ភីលីព ៤:១០-២០)។

២. ព័ន្ធកិច្ចគ្រីស្ទបរិស័ទរបស់យើងត្រូវតែពោរពេញដោយដំណឹងល្អគឺ ការអធិប្បាយនិងការបង្រៀនរបស់យើងត្រូវតែផ្ដោតលើទ្រង់ ការប្រឹក្សាយោបល់របស់យើងនៅក្នុងពួកជំនុំត្រូវតែផ្ដោតលើទំនាក់ទំនងរបស់យើងជាមួយទ្រង់ (នេះជាចំលើយចុងក្រោយបំផុតចំពោះបញ្ហាប្រឹក្សាយោបល់ទាំងឡាយ) ការថ្វាយបង្គំនិងការប្រជុំអធិស្ឋានរបស់យើងត្រូវតែផ្ដោតលើទ្រង់ គ្រប់ទាំងកម្មវិធី

> និងបេសកកម្មពួកជំនុំរបស់យើងត្រូវតែបញ្ចប់នៅក្នុងទ្រង់។ នេះគឺជាមូលហេតុដែលយើងធ្វើដូច្នេះ នៅពេលយើងថ្វាយសិរីល្អដល់ព្រះអម្ចាស់ព្រះយេស៊ូវគ្រីស្ទនិងរីករាយក្នុងការងារប្រោសលោះរបស់ទ្រង់ នោះយើងថ្វាយសិរីល្អដល់ព្រះត្រៃឯក ដែលបានសំដែងអង្គទ្រង់ឲ្យយើងស្គាល់ច្បាស់នៅក្នុងព្រះគ្រីស្ទ។

សេចក្តីប្រោសលោះរបស់ព្រះគ្រីស្ទស្ថិតនៅកណ្តាលនៃទេវសាស្ត្រគ្រីស្ទ

## កំណត់

១. ទីនេះនិងពេញក្នុងជំពូកនេះគឺជាសេចក្តីដកស្រង់ចេញពីសេចក្តីថ្លែងអំពីសេចក្តីជំនឿរបស់ក្រុមចម្រុះដំណឹងល្អ។

២. ខគម្ពីរយោងដែលត្រូវបានដកស្រង់ចេញពីព្រះគម្ពីរខ្មែរបរិសុទ្ធ (១៩៥៤)។

៣. Frank Houghton, "Thou Who Wast Rich" (1894–1972)។